

# សន្តិភាព

ចូរផ្ទេររាល់ការខ្វល់ខ្វាយទាំងអស់របស់អ្នកទៅលើព្រះអង្គ


ចយស៍ ម៉ៃយ័រ

អ្នកនិពន្ធដែលលក់ដាច់បំផុតនៅញូវយ៉កថែម

# សន្តិភាព

## សូមថ្វាយគ្រប់ទាំងបន្ទុកទៅព្រះជាម្ចាស់


**និពន្ធដោយៈ**

**អ្នកស្រី ចយស៍ ម៉ៃយ័រ**

Joyce Meyer


**បកប្រែនិងកែសម្រួលដោយៈ**

**វេជ្ជ.យ៉ែម ទេវីនាថ**


JOYCE MEYER MINISTRIES

ប្រអប់សំបុត្រលេខ ៥៤៨, ភ្នំពេញ

ព្រះបន្ទូលនៅក្នុងសៀវភៅនេះត្រូវបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ
និង ព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន។

# សេចក្ដីសុខសាន្ត

រក្សាសិទ្ធិគ្រប់យ៉ាង © 1995 ដោយ ព័ន្ធកិច្ច ចយស៏ ម៉ៃយ័រ

Printed in Cambodia

# មាតិកា


**កថាមុខ** ៤

១. តើអ្នកកំពុងតែអរសប្បាយជាមួយសន្តិភាព? ៧

២. តើធ្វើដូចម្ដេចដើម្បីអរសប្បាយជាមួយសន្តិភាព? ១៣

៣. សូមឱ្យសន្តិភាពដឹកនាំអ្នក ១៩

៤. តើអ្វីជាចោរលួចសេចក្ដីសុខសាន្តរបស់អ្នក? ២៥

៥. ហេតុអ្វីបានជាអារក្សព្យាយាមលួចសេចក្ដីសុខសាន្តរបស់អ្នក? ៣១

៦. ជំហររបស់អ្នកជឿក្នុងពេលល្បងល ៤១

៧. មួយថ្ងៃសំរាប់មួយថ្ងៃ ៤៩

៨. ការអធិស្ឋាននាំមកនូវសេចក្ដីសុខសាន្ត ៥៧

# កថាមុខ

"...ហើយត្រូវប្រព្រឹត្តល្អ និង ខិតខំស្វែងរកសេចក្ដីសុខសាន្ត។ (ភាពចុះសម្រុងគ្នា ភាពមិនរើករវរពីការភ័យខ្លាច ពីការរំជើបរំជួល និងពីទំនាស់ផ្លូវចិត្ត) ហើយចូរស្វែងរកឱ្យអស់ពីចិត្ត។ (គឺមិនត្រឹមគ្រាន់តែប្រាថ្នាចង់ទំនាក់ទំនងជាមួយព្រះជាម្ចាស់ដោយអំណរប៉ុណ្ណោះទេ ប៉ុន្តែជាមួយមិត្តភ័ក្តិស្និទ្ធស្នាល ជាមួយខ្លួនអ្នកផ្ទាល់ ចូរស្វែងរកចុះ" ។)

១ពេត្រុស ៣:១១

ខ្ញុំអធិស្ឋានឱ្យ សៀវភៅសេចក្ដីសុខសាន្តនេះ ជួយអ្នកឱ្យរៀនសប្បាយរីករាយនិងអំណរ "...សេចក្ដីសុខសាន្តរបស់ព្រះដែលហួសលើសពីអស់ទាំង គំនិត..."

(ភីលីព ៤:៧)

# តើអ្នកកំពុងតែអរសប្បាយជាមួយ
# សន្តិភាព?

# ១

# តើអ្នកកំពុងតែអរសប្បាយជាមួយសន្តិភាព?

អស់ទាំងកូនព្រះជាម្ចាស់ដែលកើតជាថ្មី គួរតែទទួលអំណរក្នុងជីវិតពេញដោយសេចក្តីសុខសាន្ត ។ព្រះយេស៊ូបានមានបន្ទូលនៅក្នុងគម្ពីរយ៉ូហាន១៤:២៧ថា

"ខ្ញុំទុកសេចក្តីសុខសាន្តឱ្យអ្នករាល់គ្នា ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឱ្យអ្នករាល់គ្នា។ សេចក្តីសុខសាន្តដែលខ្ញុំផ្តល់ឱ្យនេះ មិនដូចសេចក្តីសុខសាន្តដែលមនុស្សលោកឱ្យទេ ។ ចូរកុំរន្ធត់ចិត្ត កុំភ័យខ្លាចឱ្យសោះ ។"

នេះគឺជាបទគម្ពីរមួយដ៏មានព្រះចេស្តា ។សូមអានខគម្ពីរនេះឱ្យបានច្រើនសារ ហើយចំណាយពេលយ៉ាងហោចណាស់៥នាទីសញ្ជឹងគិតពីខគម្ពីរនេះ ហើយទទួលព្រះបន្ទូលទាំងនេះទុកក្នុងចិត្តចុះ ។

ជាបឋមសូមយើងកត់សំគាល់ថា សេចក្តីសុខសាន្តដែលព្រះយេស៊ូឱ្យមិនមែនដូចជាមនុស្សលោកឱ្យទេ ។ តើមនុស្សលោកផ្តល់ឱ្យសេចក្តីសុខសាន្តបែបណាវិញ? មនុស្សលោកគ្រាន់តែបានផ្តល់អារម្មណ៏នៃសេចក្តីសុខសាន្តតែប៉ុណ្ណោះ ។ សេចក្តីសុខសាន្តនេះកើតឡើងនៅពេលដែលដំណើរនៃជីវិតរបស់អ្នកប្រព្រឹត្តទៅតាម ផ្លូវដូចដែលអ្នកប៉ងប្រាថ្នា ។ ប៉ុន្តែ កាលណាដំណើរនៃជីវិតមិនប្រព្រឹត្តតាមផ្លូវដែលអ្នកប៉ងប្រាថ្នាទេ នោះសេចក្តីសុខសាន្តបែបមនុស្សលោកនឹងរត់ចេញពីអ្នកភ្លាម ។

វិញ្ញាណនៃ "ការតូចចិត្ត" នឹងមកគ្របដណ្តប់លើអ្នកមួយរំពេច។ តែឯសេចក្តីសុខសាន្តដែលព្រះយេស៊ូផ្តល់ឱ្យនឹងប្រព្រឹត្តទៅបានរហូត ទោះបីជាពេលរីករាយ កើតទុក្ខ សប្បូរសប្បាយ ឬក៏ត្រូវអាម៉ាស់ក្តី។ សេចក្តីសុខសាន្តរបស់ទ្រង់នឹងឈរមាំនៅនាកណ្តាលព្យុះសង្ឃរា។

ជាការប្រពៃណាស់ ដរាបណាគំនិតខាងរូបកាយនៅត្រូវបានព្រួយបារម្ភ, ប្រសិនបើអ្វីៗទាំងអស់ប្រព្រឹត្តទៅតាមផ្លូវរបស់អ្នករាល់ពេលនោះ។ ឆ្លងតាមបទពិសោធន៍ យើងដឹងថាវាមិនអាចកើតឡើងបានក្នុងជីវិតប្រចាំថ្ងៃទេ។ ក្នុងនាមជាអ្នកជឿម្នាក់ ខ្ញុំបានព្យាយាមប្រើសេចក្តីជំនឿរបស់ខ្ញុំអស់រយៈពេលជាច្រើនឆ្នាំដើម្បីនឹងដកអស់ទាំងការសៅហ្មងចេញពីជីវិត ឬ អ្វីដែលធ្វើឱ្យមានអារម្មណ៍មិនល្អ។ ការនេះបានធ្វើឱ្យខ្ញុំនឿយហត់ណាស់។ ការព្យាយាមធ្វើឱ្យអ្វីមួយកើតឡើងដែលវាមិនអាច និងមិនអាចប្រព្រឹត្តទៅកើតនោះ ជានិច្ចជាកាលវាតែងតែធ្វើឱ្យនឿយហត់ថែមទៀត។ បន្ទាប់ពីទទួលបទពិសោធន៍ខ្លះៗជាមួយព្រះជាម្ចាស់ ទីបំផុតទើបខ្ញុំដឹងថា ខ្ញុំត្រូវប្រើសេចក្តីជំនឿរបស់ខ្ញុំដើម្បីឆ្លងកាត់នូវព្យុះសង្ឃរា និងការល្បងលក្នុងជីវិតដោយស្ងប់ស្ងាត់និងដោយសន្តិភាព។ ខ្ញុំមិនអនុញ្ញាតឱ្យអារក្សលួចយកសេចក្តីសុខសាន្តរបស់ខ្ញុំ នៅពេលដែលខ្ញុំងាកឆ្វេងស្តាំនោះឡើយ។

ព្រះយេស៊ូមានបន្ទូលក្នុងគម្ពីរ យ៉ូហាន១៤:២៧ថា "កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬ ភ័យឡើយ"។ កាលណាខ្ញុំអានបទគម្ពីរនេះ និងសញ្ជឹងគិតកាន់តែច្រើននោះខ្ញុំកាន់តែយល់ដឹងពីព្រះគម្ពីរសម្តែងប្រាប់ខ្ញុំថា ខ្ញុំបានធ្វើការសំរាប់ខ្លួនខ្ញុំកាន់តែច្រើន។ ខ្ញុំត្រូវតែបញ្ឈប់វា។ រួចទ្រង់ក៏មានបន្ទូលក្នុងខនេះដែរថា "កុំឱ្យចិត្ត

អ្នករាល់គ្នា ថប់បារម្ភ ឬភ័យឡើយ" ។

ព្រះយេស៊ូបានស្តីបន្ទោសពួកសិស្សទ្រង់ក្នុងគម្ពីរម៉ាកុស៤:៤០ថា"ដោយសារពួកគេខ្វះសេចក្តីជំនឿ ទើបពួកគេបាត់សេចក្តីសុខសាន្តនៅកណ្តាលព្យុះសង្ឃរា។ តែព្រះយេស៊ូមិនបានបាត់សេចក្តីសុខសាន្តទេ។ ព្រះអង្គទ្រង់បានផ្ទុំលក់លើខ្នើយនៅកន្សៃទូក។ ពួកសិស្សរបស់ទ្រង់ នាំគ្នាភ័យខ្លាចរត់ស្លន់ស្លោគ្រប់គ្នា។

ចុះអ្នកវិញ? តើអ្នកមានអារម្មណ៍យ៉ាងណា? តើអ្នកនៅកន្សៃទូកមានសេចក្តីសុខសាន្តជាមួយព្រះយេស៊ូឬទេ? ប្រសិនបើ អ្នកមិនមានសេចក្តីសុខសាន្តទេនោះ អ្នកនឹងមិនមានអំណរក្នុងជីវិតទេ។

# តើអរសប្បាយជាមួយ
# សន្តិភាពយ៉ាងដូចម្តេច?

# ២

# តើអរសប្បាយជាមួយសន្តិភាពយ៉ាងដូចម្ដេច?

គ្មានមេរៀនណាមួយមានប្រយោជន៍ទេ លុះត្រាតែមានការណែនាំខ្លះៗដែលត្រូវបានគេផ្ដល់ឱ្យពី"របៀបធ្វើ"ឱ្យបានក្បោះក្បាយដែលអ្នកត្រូវការ ។ការនិយាយថាអ្នកត្រូវការសេចក្ដីសុខសាន្ត នេះជាជំហានទីមួយ ។ ប៉ុន្តែដោយគ្មានចែករំលែកជាក់ស្តែងពីលក្ខណៈធ្វើយ៉ាងម៉េចឱ្យទទួលបានសេចក្ដីសុខសាន្តនោះ ក៏មិនកើតផលផ្លែពិតប្រាកដដែរ ។

មានការមួយបានជួយខ្ញុំយ៉ាងខ្លាំងដើម្បីចាប់ផ្តើមធ្វើឱ្យជីវិតខ្ញុំរីករាយ ដោយសេចក្ដីសុខសាន្ត ។ ខ្ញុំបានដឹងថាវាគ្មានប្រយោជន៍ទាល់តែសោះ ហើយធ្វើឱ្យនឿយហត់ខ្លាំងណាស់ "ដើម្បីព្យាយាមធ្វើអ្វីមួយដែល ខ្ញុំមិនអាចធ្វើទៅកើតអំពីការនោះ" ។ តើអ្នកមានបានធ្វើដូច្នេះឬទេ? តើអ្នកមាននឿយហត់ខ្លាំង ឬ រសាយចិត្តដើម្បីធ្វើឱ្យអ្វីមួយបានកើតមានឡើងឬទេ? ព្រះជាម្ចាស់បានរៀបចំពេលវេលាដ៏ល្អឥតខ្ចោះសំរាប់អ្វីៗទាំងអស់ ។ អ្នកត្រូវតែរងចាំពេលវេលារបស់ផងទ្រង់ ។

ជាទូទៅអ្នកមិនអាចធ្វើអ្វីមួយឱ្យកើតខុស ពីរដូវកាលរបស់វាបានទេ ។ ទោះបើអ្នកអាចបង្កើតវាខុសរដូវកាលក៏ដោយ ក៏អ្នកនឹងមិនពេញចិត្តនូវលទ្ធផលវា

ដែរ។ ដូច្នេះចូររៀនរង់ចាំពេលទ្រង់។ ការនោះនឹងលើកតំកើងកិត្តិនាម និង ក៏នាំឱ្យអ្នកមានសេចក្តីសុខសាន្តដែរ។

តើអ្នកកំពុងតែព្យាយាមធ្វើអ្វីមួយដែលមិនអាចធ្វើទៅរួច? តើអ្នកកំពុងតែព្យាយាមបំផ្លាស់បំប្រែមនុស្សនៅជុំវិញខ្លួនអ្នកទេ? ដូចជាមនុស្សដែលអ្នកបានរៀបការជាមួយ ជាកូនម្នាក់ ជាពួកម៉ាក ឬក៏ជាសាច់ញាតិ? មនុស្សមិនអាចបំផ្លាស់បំប្រែមនុស្សបានទេ។ មានតែព្រះជាម្ចាស់មួយអង្គគត់ ដែលអាចចូលទៅក្នុងចិត្តមនុស្សបាន ហើយបណ្តាលចិត្តឱ្យគេចង់ផ្លាស់ប្រែ។ បើសិនជាយើងបង្ខំមនុស្សពីសំបកខាងក្រៅ នោះគេនឹងលួចសេចក្តីសុខសាន្តរបស់អ្នករាល់គ្នា។ ព្រះជាម្ចាស់មិនបានបង្កើតយើងឱ្យនៅក្រោមក្រិត្យវិន័យទេ។ មនុស្សត្រូវការសេរីភាព។ ពួកគេត្រូវរើចូលកន្លែងទំនេរ។

កាលពួកយើងទើបតែរៀបការបានប៉ុន្មានឆ្នាំដំបូង ខ្ញុំបានព្យាយាមបង្ខំដេវប្តីរបស់ខ្ញុំឱ្យគាត់ឈប់លេងកូនហ្គោល។ ខ្ញុំមានអារម្មណ៍ថា គាត់លេងច្រើនពេកហើយ ខ្ញុំចង់នៅជាមួយគាត់ឱ្យបានច្រើន។ ខ្ញុំព្យាយាមប្រើគ្រប់វិធីសាស្ត្រតាមដែលអាចធ្វើទៅបាន។ ខ្ញុំប្រើគ្រប់ល្បិចកលដើម្បីបញ្ឈប់គាត់។ ខ្ញុំខ្ញាញ់គាត់។ ខ្ញុំធ្វើជាខឹងគាត់។ ខ្ញុំព្យាយាមលួងលោមគាត់។ ខ្ញុំមិននិយាយរកគាត់។ តែគ្មានបានផលសោះ។ ខ្ញុំមានការបាក់ទឹកចិត្តខូចចិត្តរាល់ពេល។ ម្តងនោះគាត់បានឈប់លេងកូនហ្គោលមួយរយៈ។ ខ្ញុំកត់សំគាល់ថា ទោះបីខ្ញុំបានសំរេចដូចបំណងក៏ពិតមែនតែខ្ញុំគ្មានសន្តិភាពក្នុងចិត្តសោះ ដោយសារតែខ្ញុំឈ្នះដោយប្រើល្បិចខូច។ បើអ្នកកំពុងតែព្យាយាមបង្ខំនរណាម្នាក់ឱ្យផ្លាស់ប្រែនោះអ្នកនឹងបាត់សេចក្តីសុខសាន្ត។

# តើអរសប្បាយសន្តិភាពយ៉ាងដូចម្តេច?

តើអ្នកតូចចិត្តនឹងខ្លួនអ្នកឬ ដែលអ្នកមិននៅ កន្លែងដែលអ្នកចូលចិត្តនៅខាងឯវិញ្ញាណ? តើអ្នកកំពុងតែព្យាយាមបំផ្លាស់បំប្រែខ្លួនអ្នកឬ? ពិតប្រាកដណាស់អ្នកត្រូវរួមសហការជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធនូវការងារណា ដែលទ្រង់កំពុងធ្វើក្នុងជីវិតអ្នក។ ព្រះទ្រង់នឹងនាំអ្នកទៅរកសេចក្តីគ្រប់លក្ខណ៍និងការចាស់ទុំខាងឯវិញ្ញាណ។ អ្នកមិនអាចធ្វើខ្លួនឯងបានទេ។ នេះគឺជាផ្នែកមួយផ្សេងទៀតនៃការព្យាយាមធ្វើអ្វីមួយដែលអ្នកមិនអាចធ្វើបាន។

ខ្ញុំដឹងប្រាកដក្នុងចិត្តថា អ្នកអាចឃើញថា វា ជារឿងធម្មតាណាស់ទៅហើយដើម្បីព្យាយាមផ្លាស់ប្តូរអ្វីមួយដែលអ្នកមិនចូលចិត្តសោះ។ចូរអ្នកមានភាពប្រាកដប្រជាថា តើអ្នកអាចបំផ្លាស់បំប្រែការទាំងនេះ ឱ្យទទួលជោគជ័យដោយវិធីណា? តើអ្នកកំពុងតែនឿយហត់នឹងខ្លួនឯង និង បាត់សេចក្តីសុខសាន្តរបស់អ្នក នៅពេលអ្នកគួរតែកំពុងត្រូវបានសំរាកក្នុងទ្រង់ កំពុងរង់ចាំទ្រង់និងពេលវេលារបស់ទ្រង់ ហើយកំពុងតែទុកចិត្តដល់ទ្រង់ជាមួយអ្នកដទៃផ្សេងទៀត នៅក្នុងជីវិតរបស់អ្នក និងទោះបីជាជាមួយខ្លួនអ្នកផ្ទាល់?

សរុបសេចក្តីមកខ្ញុំអាចនិយាយបានយ៉ាងដូចនេះថាៈបើសិនជាអ្នក "ព្យាយាមធ្វើអ្វីមួយដែលអ្នកពុំអាចធ្វើទៅបាន"នោះអ្នកនឹងរសាយចិត្ត ហើយនឹងគ្មានអំណរក្នុងសេចក្តីសុខសាន្តទេ។

# សូមឱ្យសន្តិភាពដឹកនាំអ្នក

# ៣

# ចូរឱ្យសន្តិភាពបានដឹកនាំអ្នក

គម្ពីរ កូឡូស ៣:១៥ ចែងថា"សូមឱ្យសេចក្ដីសុខសាន្តរបស់ព្រះគ្រិស្ដ សោយរាជនៅក្នុងចិត្តបងប្អូន ព្រោះព្រះជាម្ចាស់បានត្រាស់ហៅបងប្អូនឱ្យមករួមគ្នាក្នុងព្រះកាយតែមួយ ដើម្បីឱ្យបងប្អូនប្រកបដោយ សេចក្ដីសុខសាន្ត...។"

នៅក្នុងកីឡាបាល់ទាត់អាជ្ញាកណ្ដាលជាអ្នកកាត់សេចក្ដីថា តើអ្នកគួរតែឈប់ ឬបន្តលេងទៀត។ រីឯសេចក្ដីសុខសាន្តវិញជាអាជ្ញាកណ្ដាលកាត់សេចក្ដីថា ការនេះគួរតែនៅក្នុងជីវិតអ្នក ឬក៏មិនគួរ។

មានមនុស្សជាច្រើនណាស់ ដែលមិនអរសប្បាយនឹងសេចក្ដីសុខសាន្តទេ ពីព្រោះពួកគេស្ថិតនៅខាងក្រៅបំណងព្រះហឫទ័យព្រះជាម្ចាស់។ ពួកគេធ្វើតាមអំពើចិត្តជាជាងធ្វើតាមបំណងព្រះហឫទ័យព្រះជាម្ចាស់។ ពួកគេធ្វើតាមអារម្មណ៍អ្វីមួយដែលពួកគេគិតថាត្រឹមត្រូវ ជាជាងធ្វើតាមព្រះបន្ទូលរបស់ទ្រង់ និង ការដឹកនាំរបស់សេចក្ដីសុខសាន្ត។ ជារឿយៗការងារខ្លះកើតមកចំពេលយើងចង់ធ្វើ។ វាល្អណាស់ ពេញចិត្តណាស់ ហើយប្រហែលជាអាចជារឿងល្អផង។ តែបើខ្ញុំគ្មានសន្តិភាពក្នុងចិត្ត ខ្ញុំត្រូវរៀនបោះបង់វាចោលវិញ ។ ចូរឱ្យសេចក្ដីសុខសាន្តជាអ្នក

ដឹកនាំវិញ។ មិនបញ្ហាទេ ទោះបីជាអ្នកចង់វាយ៉ាងណាក្តី អ្នកនឹងទទួលការសោក ស្តាយក្រោយ ប្រសិនបើអ្នកប្រឆាំងតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។

យូរៗម្តង គេបានអញ្ជើញខ្ញុំ ឱ្យចែកចាយក្នុងពិធីភ្ជាប់ពាក្យ ដែល ខ្ញុំចូលចិត្ត ណាស់ ប៉ុន្តែខ្ញុំគ្មានសន្តិភាពនឹងធ្វើវាសោះ។ ខ្ញុំមិនដឹងថាមកពីហេតុអ្វីទេ ប៉ុន្តែ ពេលខ្លះហាក់បីដូចជាគ្មានសន្តិភាពនៅទីនោះសោះ។ ខ្ញុំបានកត់សំគាល់ឃើញថា បើខ្ញុំព្រមទទួល នោះចេះតែមានហេតុផលនេះ ហេតុផលនោះប្រាប់ខ្ញុំ ហេតុអ្វីចាំ បាច់ធ្វើតាមសេចក្តីសុខសាន្ត។

ខ្ញុំនឹកចាំបានថាមានពិធីភ្ជាប់ពាក្យមួយដែលនៅពេលខ្ញុំកំពុងធ្វើដំណើរកំសាន្ត ជាលើកទីមួយ។ ខ្ញុំកម្រចែកចាយក្នុងពិធីភ្ជាប់ពាក្យណាស់ហើយនៅឆ្ងាយទៀត។ តាមធម្មតាខ្ញុំចង់ទទួលទាំងពីរ។ ខ្ញុំបានទទួលលិខិតអញ្ជើញទៅចែកចាយនៅព្រះ វិហារមួយក្នុងរដ្ឋតិចសាស។ ខ្ញុំពេញចិត្តមែនទែន។ ខ្ញុំបានឆ្លើយភ្លាមថា "ចាស៎! បាន"។ ពីរបីសប្តាហ៍ក្រោយមក ការនោះបានធ្វើឱ្យអារម្មណ៍របស់ខ្ញុំមិនស្រួល សោះ រាល់ពេលឱ្យតែខ្ញុំគិត។វាធ្វើឱ្យខ្ញុំពិបាកទៅៗ។ ខ្ញុំគ្មានសន្តិភាពនៅក្នុងចិត្តទេ ហើយព្រះជាម្ចាស់ក៏មិនប្រាប់ខ្ញុំថាមានមូលហេតុអ្វីសោះឡើយ។

ខ្ញុំបានរង់ចាំហើយរង់ចាំទៀត។ ទីបំផុត ទើបខ្ញុំដឹងថាខ្ញុំត្រូវតែទូរស័ព្ទប្រាប់គេ ថា ខ្ញុំប្រហែលជាមិនបានចូលរួមទេ។ ខ្ញុំប្រាប់គេថា ខ្ញុំនឹងទៅប្រសិនបើគេរកអ្នក ជំនួសខ្ញុំមិនបាន ប៉ុន្តែខ្ញុំគ្មានសន្តិភាពក្នុងការទៅចូលរួមទាល់តែសោះ។ គេក៏បាន ប្រាប់ខ្ញុំវិញថា គេរកមនុស្សជំនួសបានហើយ។

# សូមឱ្យសេចក្តីសុខសាន្តដឹកនាំអ្នក

ពីរបីសប្តាហ៍ក្រោយមកខ្ញុំបានដឹងថា ពួកជំនុំក្នុងស្រុកខ្ញុំធ្វើពិធីសម្ពោធអាគារថ្មីចំពេលចុងសប្តាហ៍ដែលខ្ញុំត្រូវនឹងចាកចេញទៅក្រៅ។ ខ្ញុំធ្លាប់ធ្វើជាគ្រូជំនួយក្នុងព្រះវិហារនោះមួយរយៈពេលដែរ មុនពេលខ្ញុំចាប់ផ្តើមធ្វើព័ន្ធកិច្ចផ្ទាល់ខ្លួនរបស់ខ្ញុំ ហើយវាមានសារៈសំខាន់ណាស់សំរាប់ខ្ញុំចូលរួមជាមួយពួកគេនាឱកាសនោះ។

ហេតុអ្វីបានជាព្រះជាម្ចាស់មិនមានបន្ទូលមកកាន់ខ្ញុំថា នឹងមានអ្វីកើតឡើង? តែពេលខ្លះទ្រង់មិនធ្វើដូច្នោះទេ។ ព្រះជាម្ចាស់មានបន្ទូលថា សូមឱ្យសេចក្តីសុខសាន្តបានដឹកនាំអ្នក។ ជារឿយៗទ្រង់នឹងប្រាប់អ្នកឱ្យដឹងថា អ្នកនៅខាងក្នុង ឬក្រៅបំណងព្រះហឫទ័យព្រះជាម្ចាស់។ ក្រោយមកអ្នកនឹងដឹងពីមូលហេតុនោះ ឬអ្នកប្រហែលជាមិនអាចដឹងពីមូលហេតុនោះទាល់តែសោះ។

អ្នកនឹងមិនដែលអរសប្បាយនឹងជីវិតដែល ពោរពេញដោយក្តីសុខសាន្តនោះឡើយ បើសិនជាអ្នកមិនស្តាប់បង្គាប់តាមការដឹកនាំរបស់ព្រះជាម្ចាស់ ហើយ អ្នកដើរតាមចំណង់ចំណូលចិត្តផ្ទាល់ខ្លួនវិញនោះ។

# តើអ្នកណាជាចោរលួចសេចក្តី
# សុខសាន្តរបស់អ្នក?

# ៤

# តើអ្នកណាជាចោរលួចសេចក្ដី សុខសាន្តរបស់អ្នក?

មនុស្សម្នាក់ៗតែងទទួលការរំខានពីអ្វីមួយ។ អារក្សសាតាំងបានចំណាយពេលសិក្សាមួយជីវិតរបស់អ្នកពេញ។ វាប្រហែលជាស្គាល់អ្នកជាងអ្នកស្គាល់ខ្លួនឯងទៅទៀត។ វាដឹងថាការអ្វីដែលជាការរំខានដល់អ្នកបាន។ អ្នកត្រូវតែសិក្សាឱ្យដឹងច្បាស់ថាការអ្វីខ្លះដែលរំខានអ្នក ហើយចូរប្រុងប្រយ័ត្នគ្រប់ពេលក្រែងលោហ៍អ្នកបាត់សេចក្ដីសុខសាន្តរបស់អ្នក។

ចោរលួច"សេចក្ដីសុខសាន្តរបស់អ្នករាល់គ្នា" មិនដូចគ្នាទេ។ មានរបស់ខ្លះដែលរំខានដល់ខ្ញុំ តែមិនរំខានដេវប្ដីខ្ញុំទេ។ ឧទាហរណ៍ដូចជា ខ្ញុំចូលចិត្តភាពស្ងប់ស្ងាត់ ប៉ុន្តែ សំឡេងឡូឡាមិនរំខានដេវទេ។ ដេវប្ដីខ្ញុំគាត់អាចអានសៀវភៅបានទោះបី ជាកូនស្រីខ្ញុំបើកម៉ាញ៉េឮខ្លាំងៗ និងកូនប្រុសអាយុ៩ឆ្នាំរបស់យើងកំពុងតែប្រលែងលេងជាមួយនឹងឆ្កែនៅលើកំរាលឥដ្ឋក្ដី។

ខ្ញុំមិនចូលចិត្តធ្វើអ្វីប្រញាប់ប្រញាល់ពេកទេ ហើយខ្ញុំក៏មិនចូលចិត្តយឺតយ៉ាវ

ទាល់តែសោះ ។ ជួនកាល ដេវប្ដីខ្ញុំគាត់ព្យាយាមបែងចែកពេលយ៉ាងល្អិតល្អន់ ។ យើងនឹងបង្ហើយការងារនៅសល់នាមួយនាទីចុងក្រោយ ។ នេះជាចំណែកខ្លះ ដែលអារក្សស្គាល់ពីខ្ញុំ ហើយអារក្សវាប្រើការនេះ ដើម្បីព្យាយាមលួចសេចក្ដីសុខសាន្តរបស់ខ្ញុំ ។ ម្យ៉ាងវិញទៀត ដេវប្ដីខ្ញុំ ចូលចិត្តទៅព្រលានយន្តហោះឱ្យបានមួយម៉ោងមុនពេលយន្តហោះចេញដំណើរពេលធ្វើដំណើរម្ដងៗ ។ គាត់ចូលចិត្តទៅវាយកូនហ្គោលមុនពេលលេងបន្តិច ។ បើសិនជាសាតាំងអាចរៀបចំឱ្យគាត់ចូលរួមព្រឹត្តិការណ៍ទាំងនោះយឺត នោះគាត់ចាប់ផ្ដើមបាត់សន្តិភាពក្នុងចិត្តគាត់ភ្លាម ។

យើងជាមនុស្សមានលក្ខណៈខុសប្លែកពីគ្នា ។ហេតុដូច្នេះហើយ បានជាសាតាំងប្រើគ្រប់ឧបាយកលផ្សេងៗពីគ្នាចំពោះយើងម្នាក់ៗខុសគ្នាដែរ ។ សូមឱ្យយើងមានប្រាជ្ញា ។ វារៀបចំធ្វើឱ្យអ្នកបាត់អំណរ កើតទុក្ខព្រួយ ។ តើអ្នកណាជាចោរលួចសេចក្ដីសុខសាន្តរបស់អ្នក? ចូរសរសេរវានៅក្នុងបញ្ជីមួយ ហើយពិភាក្សាជាមួយគ្រួសាររបស់អ្នក ។ ចូរស្វែងរកមើលថាតើអ្វី ធ្វើឱ្យអ្នកទប់កំហឹងមិនបាន ហើយព្យាយាមជួយគ្នាទៅវិញទៅមកដើម្បីជៀសវាងពីកន្លែងទាំងនោះ ។

ដេវប្ដីខ្ញុំជាអ្នកចូលចិត្តលេងកូនហ្គោលយ៉ាងខ្លាំង ។ ខ្ញុំចេះលេង ប៉ុន្តែខ្ញុំគ្រាន់តែលេងកំសាន្តសប្បាយតែប៉ុណ្ណោះ ។ ខ្ញុំបានរៀនលេង តែទោះជាយ៉ាងណាក៏ខ្ញុំលេងមិនពូកែដែរ ។ ពេលលេងជាមួយប្ដីខ្ញុំម្ដងៗ ក៏ខ្ញុំចូលចិត្តញ៉ោះគាត់ពេលណាគាត់ស៊ុតមិនចូលរន្ធម្ដងៗ ។ យើងសើចសប្បាយជាមួយគ្នា ក៏ប៉ុន្តែខ្ញុំត្រូវធ្វើអ្វីដើម្បី

ឱ្យស្វាមីរបស់ខ្ញុំគាត់មានសេចក្ដីសុខស្រួល ផាសុកភាព។ វាគ្មានប្រយោជន៍ និងគ្មានមនសិការទាល់តែសោះក្នុងការធ្វើឱ្យអ្នកណាម្នាក់បាត់សន្តិភាព ក្នុងចិត្តរបស់គេ។ កាលណាអ្នករស់នៅជាមួយអ្នកណាម្នាក់អស់រយៈពេលដ៏យូរ នោះអ្នកនឹងស្គាល់ចំណុចខ្សោយរបស់គេ ក៏ដូចជារបស់អ្នកដែរ។ ខ្ញុំសូមរំលឹកម្ដងទៀតថា "សូមព្យាយាមជួយគ្នាទៅវិញទៅមកឱ្យជៀសវាងពីកន្លែងខ្សោយទាំងនោះ"។

ដេវប្ដីខ្ញុំជួយស្ដារចំណុចខ្សោយរបស់ខ្ញុំ។ គាត់ព្យាយាមរក្សាភាពស្ងៀមស្ងាត់នាពេលខ្ញុំកំពុងព្យាយាមសិក្សាឬក៏កំពុងសំរាក។ គាត់លើកទឹកចិត្តខ្ញុំឱ្យសំរាក និងបង្កើតការកំសាន្តសប្បាយ ពីព្រោះគាត់ដឹងថា កាលណាខ្ញុំនឿយហត់ហួសកម្លាំង នោះសាតាំងនឹងលួចសេចក្ដីសុខសាន្តរបស់ខ្ញុំ។ ក្នុងព្រះគម្ពីរកាឡាទី៦:២ និយាយថា "ចូរយកអាសាគ្នាទៅវិញទៅមក..."។ យើងត្រូវជួយគ្នាកាលណាយើងទន់ខ្សោយហើយត្រូវដឹងថាយើងមានចំណុចខ្សោយច្រើនណាស់។ យើងត្រូវអធិស្ឋានឱ្យគ្នាទៅវិញទៅមក។

# ហេតុអ្វីបានជាអារក្សសាតាំងព្យាយាម
# លួចសេចក្តីសុខសាន្តរបស់អ្នក?

# ៥

# ហេតុអ្វីបានជាអារក្សសាតាំងព្យាយាមលួចសេចក្ដីសុខសាន្តរបស់អ្នក?

យើងដឹងថា សេចក្ដីសុខសាន្តបានចងភ្ជាប់ជាមួយព្រះវិញ្ញាណបរិសុទ្ធ។ យើងអាចនិយាយបានម្យ៉ាងទៀតថា ព្រះវិញ្ញាណបរិសុទ្ធធ្វើការតែក្នុងរង្វង់មជ្ឈដ្ឋាននៃភាពសុខសាន្តតែប៉ុណ្ណោះ។ មានអំណាចនៅក្នុងសេចក្ដីសុខសាន្ត។ ខ្ញុំជឿ បានជាហេតុអ្វីលោកយ៉ូហានបានប្រាប់យើង(យ៉ូហាន១៤:២៧) ថាកេរដំណែលរបស់ព្រះគ្រិស្ដសំរាប់យើងគឺសេចក្ដីសុខសាន្ត។ ព្រះយេស៊ូមានបន្ទូលថា"...សេចក្ដីសុខរបស់ខ្ញុំបានទុកឱ្យដល់អ្នករាល់គ្នា"។ ពាក្យមួយផ្សេងទៀតគឺព្រះទ្រង់មានព្រះហប្ញទ័យចែកសេចក្ដីសុខសាន្តរបស់ទ្រង់ឱ្យដល់យើង។

នៅពេលអ្នកមានបញ្ហា ហើយអារក្សមិនអាចធ្វើឱ្យអ្នកកើតទុក្ខព្រួយបាន មានន័យថា វាគ្មានអំណាចលើអ្នកទេ។ អំណាចរបស់អ្នកនឹងរក្សាភាពស្ងប់ស្ងាត់ពេញដោយសុខសន្តិភាព និងឥរិយាបថទុកចិត្ត។ អំណាចរបស់អារក្សធ្វើឱ្យអ្នកកើតទុក្ខព្រួយ និងពេញទៅដោយ ការភ័យខ្លាចតែប៉ុណ្ណោះ។

# សន្តិភាព

នៅពេលអ្នកដឹងថាខ្លួនអ្នកស្ថិតក្នុងស្ថានភាពពិបាក ខ្វល់ខ្វាយ សូមឱ្យគោលបំណងរបស់អ្នកស្ថិតក្នុងសភាពស្ងប់ស្ងាត់ជាធម្មតា។ កុំបណ្តោយខ្លួនឱ្យធ្លាក់ក្នុងកណ្តាប់ដៃរបស់អារក្សសាតាំងដោយការពិបាកចិត្តនោះឡើយ។ ដ្បិតអារក្សសាតាំងវាសប្បាយរីករាយ ក្នុងការធ្វើឱ្យអារម្មណ៍របស់អ្នកខ្វល់ខ្វាយ។ ជាញឹកញាប់កិច្ចការដំបូងបំផុតដែលមនុស្សធ្វើនៅក្នុងពេលកំពុងតែមិនសប្បាយចិត្ត គឺនិយាយចេញពីមាត់របស់គេ ដែលឱ្យអារក្សចាក់សាំង បន្ថែមលើភ្លើងដែលវាទើបតែបានបង្កាត់រួច។

ព្រះគម្ពីរយ៉ាកុប៣:៥-៦ ចែងថា "អណ្តាតក៏ជាអវយវៈមួយយ៉ាងតូចដូច្នោះដែរ ប៉ុន្តែចេះអួតអាងយ៉ាងសំបើមណាស់ មើលចុះភ្លើងតែបន្តិចទេអាច នឹងឆេះព្រៃធំៗទៅបាន ហើយអណ្តាតក៏ជាភ្លើងដែរគឺជា លោកិយដ៏ពេញដោយសេចក្តីទុច្ចរិត"។ វាជាពិភពនៃអំពើទុច្ចរិតដែលបង្កើតនៅក្នុងចំណោមសមាជិករបស់យើង ធ្វើឱ្យរូបកាយទាំងមូលស្មោកគ្រោក ក៏បញ្ឆេះទាំងផ្លូវជីវិតផងដែរ ហើយភ្លើងនោះឆេះមកពីស្ថាននរក។ អ្នកអាចឃើញតាមរយៈបទគម្ពីរនេះថា អារក្សចង់បំបាត់ភាពម្ចាស់ការលើខ្លួនឯងរបស់យើង ដោយហេតុដូចនេះ វាអាចឆក់ឱកាសគ្រប់គ្រងលើយើងបាន។ សូមចាំថាអារក្សព្យាយាមធ្វើយ៉ាងណា ឱ្យអ្នកមិនសប្បាយចិត្ត និង មានទុក្ខកង្វល់។

អ្នកគួរកត់ចំណាំថា អារក្សវាធ្វើការបន្ថែមម៉ោង នៅពេលណាអ្នកត្រៀមខ្លួន

ទៅព្រះវិហារ ឬ ក៏ទៅរៀនព្រះបន្ទូល។ រៀងរាល់ព្រឹកថ្ងៃអាទិត្យនៅម្តុំផ្ទះរបស់យើងហាក់បីដូចជាមានពិធីជប់លៀងយ៉ាងធំអស់រយៈពេលជាច្រើនឆ្នាំ។ យើងកម្រទៅព្រះវិហារដោយគ្មាននរណាម្នាក់មិនសប្បាយចិត្តនោះទេ។

នៅព្រឹកថ្ងៃអាទិត្យមានការបាត់របស់របរ របស់កំពប់ ហើយ បែកបាក់ មិនដូចថ្ងៃសព្វដងសោះ។ កូនរបស់យើងចេះស្រឡាញ់គ្នា មិនដែលមានបញ្ហាអ្វីទេពេញមួយសប្តាហ៍ ប៉ុន្តែនៅពេលព្រឹកថ្ងៃអាទិត្យគេឈ្លោះប្រកែកគ្នា។ កាលណាមានសម្លេងឡូឡា និងភាពច្របូកច្របល់កាន់តែច្រើន នោះខ្ញុំពិបាកចិត្តកាន់តែខ្លាំង (ដូចអ្នកដឹងហើយថា ខ្ញុំមិនចូលចិត្ត សំឡេងឡូឡាខ្លាំងពេកទេ)។

ទីបំផុត ខ្ញុំចាប់ផ្តើមចេះត្អូញត្អែរ។ តែដេវប្តីខ្ញុំមិនចូលចិត្តការត្អូញត្អែរទេ។ ដូច្នេះ មួយសន្ទុះក្រោយមកគាត់បានប្រាប់ខ្ញុំឱ្យឈប់ត្អូញត្អែរទៀត។ ម្ល៉ោះហើយបានធ្វើឱ្យខ្ញុំខឹងគាត់។ ពេលនោះកូនៗក៏ស្រែកយំ ពីព្រោះឃើញខ្ញុំឈ្លោះគ្នា។

នៅក្នុងចន្លោះពេលនោះដែរ ឆ្កែខាំពាំស្បែកជើងរបស់អ្នកណាម្នាក់ដែលត្រូវពាក់រត់ពេញផ្ទះ រកស្បែកជើងពាក់មិនបាន ពេលនោះខ្ញុំបានចាប់ផ្តើមស្រែកឡើងថា "ប្រញាប់ឡើង! យើងទៅព្រះវិហារយឺតហើយ!" ខ្ញុំជឿជាក់ថាអ្នកស្គាល់ស្ថានភាពបែបនេះ។

នៅពេលខ្ញុំបានឃើញគម្ពីរយ៉ាកុប៣:១៨ ខ្ញុំបានយល់ថា តើហេតុអ្វីហាក់បីដូចជាការនេះកើតឡើងជានិច្ច នៅពេលយើងមានបំណងនឹងចេញទៅទទួលព្រះ

បន្ទូលព្រះជាម្ចាស់។ ព្រះគម្ពីរថែងថា"អស់អ្នកកសាងសន្តិភាព(សេចក្តីសុខសាន្ត) តែងសាបព្រោះសន្តិភាព ហើយ ច្រូតយកផលជាជីវិតសុចរិត"។

ម្យ៉ាងវិញទៀតដើម្បីឱ្យព្រះបន្ទូលព្រះជាម្ចាស់បានចាក់ឫស និង បង្កើតជាផ្លែល្អក្នុងជីវិតរបស់យើងនោះ យើងត្រូវទទួលការចែកចាយ ឬ បង្ហាត់បង្រៀនដោយអ្នកដែលធ្លាប់បង្កើតសេចក្តីសុខសាន្ត។ យើងត្រូវមានឥរិយាបថប្រកបដោយសេចក្តីសុខសាន្ត ពេលណាឮព្រះបន្ទូលព្រះផងដែរ។

ចូរសញ្ជឹងគិតពីជីវិតផ្ទាល់ខ្លួនរបស់អ្នក។ តើខ្មាំងសត្រូវទទួលជ័យជំនះប៉ុន្មានដងក្នុងការប៉ុនប៉ងបំបាក់ទឹកចិត្តអ្នក មុនពេលអ្នកទៅស្តាប់ព្រះបន្ទូលព្រះ? ចូរប្រយ័ត្នពីផែនការរបស់វា ហើយកុំឱ្យធ្លាក់ទៅក្នុងកណ្តាប់ដៃវាឱ្យសោះ។ ព្រះគម្ពីរ ២.កូរិនថូស២:១១ ចែងថា "ដើម្បីមិនឱ្យអារក្សសាតាំងមានឱកាសនឹងឈ្នះយើងបានឡើយ ត្បិតយើងស្គាល់អស់ទាំងកិច្ចកលរបស់វាហើយ"។ សាតាំងប្រើល្បិចកល្បយ៉ាងប៉ិនប្រសព្វដើម្បីបំភាន់ភ្នែក ហើយនាំឱ្យយើងវង្វេង។ សូមឱ្យយើងមានគំនិតវាងវៃជាងខ្មាំងសត្រូវរបស់យើងគឺជាងអារក្ស។

ព្រះគម្ពីរ ១ពេត្រុស៥:៨ ចែងថា " ចូរឱ្យដឹងខ្លួនហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែលទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន"។

សូមកុំឱ្យការនោះកើតដល់អ្នកឱ្យសោះ! ខ្ញុំសូមដាស់តឿនអ្នកចូរឱ្យប្រុងប្រ

យ័ត្ន។ រាល់ពេលអ្នកមានអារម្មណ៍តូចចិត្តឬក៏រសាយចិត្ត ចូរឈប់និងសួរខ្លួនឯងថា "តើអារក្សកំពុងព្យាយាមធ្វើអ្វី? ប្រសិនបើខ្ញុំមានចន្លោះអវិជ្ជមានក្នុងគំនិត តើខ្ញុំនឹងទទួលលទ្ធផលបែបណា?"

ព្រះគម្ពីរ អេភេសូរ៤:២៦-២៧ ជាបទគម្ពីរយ៉ាងសំខាន់ ដែលបង្រៀនយើងឱ្យរក្សាខ្លួនគេចផុតពីវិញ្ញាណអាក្រក់ ហើយកុំឱ្យមានចន្លោះក្នុងជីវិតរបស់យើងដែលនាំអ្នកឱ្យព្រួយចិត្តឡើយ។ នៅក្នុងខ២៦ចែងថា "ចូរខឹងចុះតែកុំឱ្យធ្វើបាបឡើយ កុំឱ្យសេចក្ដីកំហឹងរបស់អ្នកនៅដរាបដល់ថ្ងៃលិចឡើយ"។ ម្យ៉ាងវិញទៀតយើងអាចនិយាយបានថា"កុំពិបាកចិត្ត"។

ខ២៧ "ក៏កុំឱ្យអារក្សមានឱកាសឱ្យសោះ"។ ពេលណាអ្នកកើតទុក្ខអ្នកនឹងបាត់អំណរ។ កាលណាអ្នកបាត់អំណរ អ្នកនឹងចុះខ្សោយកម្លាំង។ ព្រះគម្ពីរនេហេមា៨:១០ ចែងថា "អំណររបស់ព្រះអង្គជាកម្លាំងនៃខ្ញុំ"។ គម្ពីរទំនុកដំកើង៤២:៥ ព្រះបាទដាវីឌនិយាយទៅកាន់ព្រលឹងខ្លួនឯងថា "ឱព្រលឹងអញអើយហេតុអ្វីបានជាត្រូវបង្អោនចុះ ហើយមានសេចក្ដីរសាប់រសល់នៅក្នុងខ្លួនដូច្នេះ ចូរសង្ឃឹមដល់ព្រះចុះ ត្បិតអញនឹងបានសរសើរដល់ទ្រង់ទៀត ដោយព្រោះព្រះភក្ត្រទ្រង់ដែលតែងតែជួយ"។ ព្រះគម្ពីរអេសាយ៣០:១៥ ចែងថា "ត្បិតព្រះអម្ចាស់យេហូវ៉ាជាព្រះដ៏បរិសុទ្ធនៃពួកអ៊ីស្រាអែល ទ្រង់មានបន្ទូលថា ឯងរាល់គ្នានឹងបានសង្គ្រោះដោយវិលមកវិញ ហើយផ្អាកសំរាកឯងរាល់គ្នានឹងមានកំឡាំងដោយនៅតែស្ងៀម

ហើយមានសេចក្តីទុកចិត្តតែឯងរាល់គ្នា..."។ ជាថ្មីម្តងទៀតយើងរាល់គ្នាដឹងថា អារក្សចង់រុកគួនយើង ដើម្បីធ្វើឱ្យយើងចុះខ្សោយកំឡាំង។

ខ្ញុំបានរៀនពីព្រះវិញ្ញាណបរិសុទ្ធថា ទ្រង់ធ្វើការក្នុងមជ្ឈដ្ឋាននៃសេចក្តីសុខសាន្ត។ ព្រះវិញ្ញាណបរិសុទ្ធមិនបានធ្វើក្នុងភាពជ្រួលច្របល់ទេ។ អារក្សធ្វើការក្នុងភាពជ្រួលច្របល់ ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងសេចក្តីសុខសាន្ត។ សូមផ្តល់បរិយាកាសពេញដោយសេចក្តីសុខសាន្តនៅក្នុងផ្ទះរបស់អ្នក, មុខជំនួញ ក្រុមជំនុំ ឬ ព័ន្ធកិច្ចរបស់អ្នក។ បើអ្នកធ្វើដូច្នោះ នោះអ្នកនឹងផ្តល់កិត្តិយសដល់ព្រះបន្ទូលរបស់ព្រះ និង ព្រះវិញ្ញាណនៃព្រះជាម្ចាស់។ អ្នកនឹងច្រូតកាត់ផលនៃការស្តាប់បង្គាប់របស់អ្នកចំពោះព្រះជាម្ចាស់។

ចូរចងចាំថា ព្រះយេស៊ូបានបញ្ជូនសិស្ស៧0នាក់ ដោយមានគ្នាពីរៗនាក់ឱ្យទៅធ្វើការ អស្ចារ្យជាច្រើនដូចជា: ដេញអារក្ស(វិញ្ញាណអាក្រក់ ប្រោសជំងឺឱ្យជា និងប្រកាសដំណឹងល្អ។ ព្រះទ្រង់បានបង្គាប់ពួកគេឱ្យចូលទៅក្នុងទីក្រុងរកផ្ទះ និងនាំសេចក្តីសុខសាន្តដល់គេ ព្រមទាំងស្នាក់នៅជាមួយគេ។ ប្រសិនបើគេមិនព្រមទទួល(ដោយសេចក្តីសុខសាន្ត) សូមគោះជើង ហើយជូតធូលីពីជើងចេញព្រមទាំងបន្តដំណើរទៅមុខទៀត។ (លូកា១០:១-១១និង១៧) ហេតុអ្វីទៅ? ការងាររបស់គេនឹងទៅជាខ្សោយប្រសិនបើគេមិនរស់នៅក្នុងសេចក្តីសុខសាន្ត។

ខ្ញុំដឹងយ៉ាងពិតប្រាកដថា អ្នកកំពុងទទួលការបើកសំដែងតាមរយៈព្រះគម្ពីរ

ដែលមាននៅក្នុងសៀវភៅនេះ។ តើអ្នកនឹងព្យាយាមម្ចាស់ការលើខ្លួនឯងដើម្បីរក្សាសេចក្ដីសុខសាន្ត ឱ្យស្ថិតស្ថេរនៅជារៀងរហូតដែរឬទេ?

នៅក្នុងព្រះគម្ពីរលូកា២២:៤៦ព្រះយេស៊ូបានបង្រៀនយើងឱ្យអធិស្ឋានដើម្បីកុំឱ្យធ្លាក់ទៅក្នុងសេចក្ដីល្បួង។ ព្រះទ្រង់មានបន្ទូលទៅពួកសិស្សទ្រង់ថា "...ចូរក្រោកឡើង ហើយអធិស្ឋានចុះដើម្បីកុំឱ្យត្រូវសេចក្ដីល្បួង"។ កុំឱ្យពឹងផ្អែកលើខ្លួនឯងឬកំឡាំងរបស់អ្នកដើម្បី ទប់ទល់នឹងវិញ្ញាណអាក្រក់(អារក្ស) ក្នុងកន្លែងនេះឡើយ។ ចូរអធិស្ឋានជារៀងរាល់ថ្ងៃ សូមឱ្យព្រះជាម្ចាស់ផ្ដល់ព្រះគុណក្នុងការទប់ទល់នឹងអារក្ស ពេលណាវាចង់លួចសេចក្ដីសុខសាន្តរបស់អ្នក។ ចូរទូលសូមដល់ព្រះអម្ចាស់ចំរើនកំឡាំង និងជួយអ្នកផងដែរ។

ចូរចងចាំព្រះគម្ពីរយ៉ូហាន១៥:៥ចែងថា "...ត្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ"។ កុំព្យាយាមធ្វើអ្វីដោយខ្លួនឯងឡើយ!ចូរសុំជំនួយពីព្រះជាម្ចាស់!។

អ្នកអាចធ្វើបានគ្រប់ការទាំងអស់ដោយសារព្រះគ្រិស្ដ ទ្រង់ចំរើនកម្លាំងឱ្យ(គម្ពីរភីលីព៤:១៣) ប៉ុន្ដែមិនមែនដោយសារខ្លួនអ្នកឡើយ។ ក្នុងព្រះគម្ពីរ យ៉ូហាន៥:៣០ សូម្បីតែព្រះយេស៊ូមានបន្ទូលថា "ខ្ញុំពុំអាចនឹងធ្វើការអ្វីដោយខ្លួនខ្ញុំបានទេ"។ អ្នកត្រូវតែមានឥរិយាបថបន្ទាបខ្លួន ប្រសិនបើអ្នកចង់ឱ្យព្រះជាម្ចាស់ជួយអ្នក។ ក្នុងព្រះគម្ពីរ១.ពេត្រុស៥:៥ ចែងថា "ព្រះទ្រង់តែងតតាំងនឹងមនុស្ស

អួតអាង តែផ្តល់ព្រះគុណដល់ពួករាបសាវិញ"។

ដូច្នេះខ្ញុំសូមសង្ខេបដោយនិយាយថា សាតាំងចង់លួចសេចក្តីសុខសាន្តរបស់អ្នក ដូច្នេះវាអាចធ្វើឱ្យអ្នកចុះខ្សោយកំឡាំង។ វាចង់ឱ្យអ្នកទៅជាខ្សោយ និងគ្មានអំណាច ប៉ុន្តែខ្ញុំសូមលើកទឹកចិត្តដល់បងប្អូនរាល់គ្នាថា "ចូរឱ្យមានកំឡាំងឡើងក្នុងព្រះអម្ចាស់ដោយឫទ្ធិបារមីរបស់ចេស្តាទ្រង់"(អេភេសូរ៦:១០)។

ចូររស់នៅប្រកបដោយសេចក្តីសុខសាន្តចុះ ។

# គោលជំហររបស់អ្នកជឿ

# ពេលជួបការល្បួងល័

# ៦

# គោលជំហររបស់អ្នកជឿ ពេលជួបការល្បងល

ព្រះគម្ពីរអេភេសូរ៦:១៣ចែងថា "...រួចកាលណាបានតតាំងសព្វគ្រប់ហើយ នោះឱ្យបាននៅតែឈរមាំមួនដដែល"។ តើអ្វីទៅជាទីកន្លែងរបស់អ្នក? ព្រះគម្ពីរអេភេសូរ២:៦បានបង្រៀនយើងថាកន្លែងរបស់យើងម្នាក់ៗនៅ ជាមួយព្រះគ្រិស្ដនៅស្ថានដ៏ខ្ពស់។ ព្រះយេស៊ូមានបន្ទូលថា"បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្ដីនោះនឹងបានសំរេចដល់អ្នករាល់គ្នាជាមិនខាន" (យ៉ូហាន១៥:៧)។ *ជំហរនៅខ្ជាប់ខ្ជួនជាទីតាំងនៃអំណាច ។*

ព្រះគម្ពីរហេព្រើរ៤បានចែងថា នៅពេលអ្នកឈប់ធ្វើការតស៊ូព្យាយាមរបស់អ្នក, ធ្វើការងារជំនួសវិញ(តាមរយៈសេចក្ដីជំនឿនិងការស្ដាប់បង្គាប់) ដើម្បីចូលទៅក្នុងការសំរាករបស់ទ្រង់ នោះអ្នកនឹងបានសំរាកជាពិត។ នៅក្នុងពេលមានការជំនុំជំរះ ចូរធ្វើអ្វីតាមព្រះជាម្ចាស់ដឹកនាំឱ្យអ្នកធ្វើចុះ, ប្រកាន់ខ្ជាប់នូវជំហានរបស់អ្នកក្នុងព្រះគ្រិស្ដ ព្រមទាំងចាំមើលទ្រង់ធ្វើការជំនួសអ្នកវិញម្ដង។ ព្រះគម្ពីរ

ថែងថា"...កុំខ្លាចអី ឈប់សិនចាំមើលសេចក្តីសង្គ្រោះរបស់ព្រះយេហូវ៉ា"(និក្ខមនំ ១៤:១៣)។ ពាក្យ "រងចាំមើល សំរាក ឈរមាំមួន ក្នុងព្រះគ្រិស្ត" សរុបសេចក្តីមកមានន័យថា កុំឱ្យសេចក្តីសុខសាន្តបាត់ពីអ្នកឡើយ!

ព្រះគម្ពីរភីលីព១:២៨ គឺជាបទគម្ពីរមួយក្នុងចំណោម បទគម្ពីរដ៏ពេញដោយអំណាចចេស្តាបំផុត ដែលនាំមកការបញ្ជាក់យ៉ាងច្បាស់ថាៈ

"ឥតមានភ័យខ្លាចចំពោះពួកទាស់ទទឹងក្នុងការអ្វីឡើយ ដំណើរនោះឯងនឹងសំដែងពីសេចក្តីហិនវិនាសរបស់គេ តែពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាវិញដែលសេចក្តីនោះបានមកពីព្រះផង"។

បទគម្ពីរនេះបានសបញ្ជាក់យ៉ាងច្បាស់លាស់។ *នៅពេលណាអ្នកទទួលរងការវាយប្រហារ ចូរស្ថិតនៅក្នុងសេចក្តីសុខសាន្ត។* ចូរបង្គាប់ទៅអារក្សថា ឯងទទួលបរាជ័យហើយ។ វាមិនដឹងជាធ្វើម្តេចជាមួយអ្នកទេ បើសិនណាវាមិនអាចធ្វើឱ្យអ្នកកើតទុក្ខព្រួយបាន។ ដោយសារឥរិយាបថនៃសេចក្តីសុខសាន្ត និងការសំរាកមកពីព្រះជាម្ចាស់ នោះបង្ហាញថា អ្នកកំពុងអនុវត្តនូវសេចក្តីជំនឿដ៏ពិតប្រាកដ។ តាមបទគម្ពីរហេព្រើរ៤បានថែងថា អស់អ្នកណាដែលចូលទៅក្នុងការសំរាករបស់ព្រះជាម្ចាស់ អ្នកនោះត្រូវតែជឿដល់ទ្រង់ ។

សូមបោះជំហានទៅមុន ហើយអរសប្បាយនឹងជីវិតរបស់អ្នក ក្នុងខណៈពេលទ្រង់ដោះស្រាយបញ្ហារបស់អ្នក។ ខ្ញុំគិតថា មនុស្សភាគច្រើនមានភាពស្រពិចស្រពិលក្នុងគំនិតហើយនិយាយថា វាមិនត្រូវសោះពេលមានបញ្ហាបែរ ជាអរសប្បាយ

ទៅវិញ។ បន្ទាប់មកទៀត ប្រសិនបើមិនអាចធ្វើអ្វីផ្សេងទៀតបាន យ៉ាងហោចណាស់ អ្នកក៏មិនអាចធ្វើឱ្យកំសត់ មានសេចក្តីវេទនានោះដែរ។

ខ្ញុំដឹងថា ខ្ញុំធ្លាប់ឆ្លងកាត់បទពិសោធន៍ជាច្រើនបែបនេះកាលពីអតីតកាល។ នៅពេលប្តីខ្ញុំ និង ខ្ញុំបានជួបប្រទះការល្បងល ឬ បញ្ហាបែបនេះក្នុងជីវិត គាត់មានអំណរវិញ។ ខ្ញុំមានទុក្ខលំបាកហើយខឹងនឹងគាត់ ដោយសារគាត់មិនព្រមទទួលទុក្ខលំបាក កំសត់ជាមួយខ្ញុំ។

បញ្ហាដែលយើងជួបប្រទះជាញឹកញាប់ប្រចាំថ្ងៃគឺ ផ្នែកហិរញ្ញវត្ថុ។ ស្វាមីខ្ញុំដេវហាក់បីដូចជាមានសេចក្តីជំនឿរឹងមាំអស្ចារ្យពីបញ្ហាលុយកាក់។ គាត់និយាយថា "យើងថ្វាយដង្វាយ១ភាគ១០ និងចែកទានដោយសេចក្តីសប្បុរស ពេលឃើញមានសេចក្តីត្រូវការចាំបាច់។ ព្រះគម្ពីរចែងថា "ចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ត្បិតទ្រង់តែងតែ យកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា"(១.ពេត្រុស៥:៧) ហើយគម្ពីរភីលីព៤:១៩ ចែងថា ទ្រង់នឹងបំពេញសេចក្តីត្រូវការរបស់យើង។ ចុះហេតុអ្វីបានជាខ្ញុំត្រូវព្រួយបារម្ភ អំពីរឿងនេះទៀត? ការខ្វល់ខ្វាយនឹងមិននាំលុយចូលផ្ទះទេ ។ គឺវាមិនធ្លាប់មានទាល់តែសោះ។

នេះគឺជាជំហររបស់ដេវដែលគាត់បានចាប់យក។ ខណៈពេលដែល ព្រះជាម្ចាស់កំពុងដោះស្រាយបញ្ហា ដេវបានជំរុលទៅមុខទៀត និងមានអំណរក្នុងជីវិតគាត់ដែរ ។ ខ្ញុំចង់និយាយថា " បងដេវខ្ញុំដឹងការទាំងអស់នោះហើយ ប៉ុន្តែអ្នកមិនមែនមិនធ្វើអ្វីសោះនោះទេ"។ ខ្ញុំចង់ឱ្យគាត់ធ្វើអ្វីមួយ។ គាត់សួរថា "តើចង់ឱ្យបងធ្វើអ្វី?"ខ្ញុំឆ្លើយប្រាប់គាត់ថា "ចូរអធិស្ឋានទៅ! បងគួរតែអធិស្ឋាន"។ គាត់ឆ្លើយ

តបវិញថា "បងបានធ្វើហើយ បងបានអធិស្ឋានរួចហើយ និងសូមឱ្យព្រះអម្ចាស់យកព្រះទ័យទុកដាក់នឹងបញ្ហានេះ"។ បងបានទូលសូមដល់ទ្រង់ឱ្យបង្ហាញប្រាប់បង ក្រែងលោហ៍ទ្រង់ចង់ឱ្យបងធ្វើអ្វីទៀត។ តែទ្រង់មិនបានបង្ហាញអ្វីប្រាប់បងសោះ ដូច្នេះបងមិនឃើញមានចំណុចណាទៀតដែលលំបាកវេទនាកំសត់នោះទេ។

ខ្ញុំដឹងពីជំរៅចិត្តខាងក្នុងថាដេវគាត់និយាយត្រូវ។ តែខ្ញុំនៅមានភាពស្រពិចស្រពិលពីបញ្ហានេះ ពីព្រោះហាក់បីដូចជាមានអ្វីមួយប្រាប់ខ្ញុំថា អ្នកមិនគួរមានអំណរពេលខ្លួនមានបញ្ហានោះទេ។ ខ្ញុំបានទទួលលទ្ធផលដដែលៗអស់រយៈពេលជាច្រើនឆ្នាំ។ គ្រប់ពេលដែលយើងមានបញ្ហា ដេវបានអធិស្ឋាន ហើយនៅស្ងៀមក្នុងសេចក្តីសុខសាន្ត ហើយខ្ញុំគិតតែអធិស្ឋានផងកើតទុក្ខផង។ ខ្ញុំធ្វើឱ្យខ្លួនឯងកើតទុក្ខព្រួយ កំសត់វេទនា។ ដេវ មានអំណរអរសប្បាយក្នុងជីវិតរបស់គាត់ ហើយទ្រង់តែងតែគង់ជាមួយរហូតដល់ចប់។ យើងតែងតែធ្វើដូច្នេះ។

អរព្រះគុណព្រះជាម្ចាស់ ទីបំផុតខ្ញុំដឹងថាអ្វីដែលខ្ញុំបានធ្វើ មិនបានទទួលផលអ្វីសោះឡើយ។ គ្រប់អ្វីដែលខ្ញុំបានធ្វើ គឺខ្ញុំបានធ្វើឱ្យខ្លួនឯងកំសត់ ហើយប្រហែលជាអាចបង្អាក់ចម្លើយរបស់ព្រះជាម្ចាស់ផង។ ឥឡូវខ្ញុំមានអំណរ សេចក្តីសុខសាន្តនៅកណ្តាលព្យុះសង្ឃរា (ម៉ាកុស ៤:៣៧-៤០)។

ព្រះយេស៊ូមានបន្ទូលថា "ខ្ញុំប្រាប់សេចក្តីទាំងនេះដើម្បីឱ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត ដោយសារខ្ញុំនៅលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែត្រូវសង្ឃឹមឡើង ត្បិតខ្ញុំបានឈ្នះលោកិយហើយ" (យ៉ូហាន១៦:៣៣)។ ព្រះគម្ពីរក៏បានថែងផងដែរថា អ្នករាល់គ្នានឹងជួបសេចក្តីល្បួង ប៉ុន្តែទ្រង់ទូន្មានយើង

កុំឱ្យធ្លាក់ទៅក្នុងសេចក្តីល្បួងឡើយ( លូកា៨:១៣,១កូរិនថូស១០:១៣ និង យ៉ាកុប១:១២) ។ ខ្ញុំចង់និយាយត្រង់ចំណុចនេះថា យើងត្រូវតែមានការខិតខំតស៊ូព្យាយាមក្នុងឆាកជីវិត ប៉ុន្តែយើងជាអ្នកមានជ័យជំនះដោយសារ ព្រះយេស៊ូគ្រិស្ត (រ៉ូម៨ :៣៧ ) ។

យើងមិនត្រឹមតែជាអ្នកបានឈ្នះទេ ប៉ុន្តែយើងតែងតែជាអ្នកឈ្នះជានិច្ច។ អ្នកនឹងមិនអាចឈោងទៅចាប់កន្លែងណាមួយ ដែលអ្នកបានមានជ័យជំនះ លើគ្រប់ឧបសគ្គនោះទេ ប៉ុន្តែអ្នកបានទទួលការធានាអះអាងពីជ័យជំនះជាដរាបក្នុងព្រះគ្រិស្ត។ អ្នកតែងតែឈ្នះជានិច្ច។

អ្នកនឹងទៅដល់កន្លែងមួយ ដែលសាវកប៉ុលបានមានប្រសាសន៍ ក្នុងគម្ពីរភីលីព៤:១១-១២ថា គាត់បានរៀនឱ្យមានសេចក្តីសន្តោសក្នុងសណ្ឋានគ្រប់យ៉ាង។ ខ្ញុំធ្លាប់ទ្រាំឱ្យមានសេចក្តីចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្តីរីករាយដែរ។ ប្រសិនបើមិនដូច្នោះទេ នោះជីវិតរបស់អ្នកនឹងមានតែការពិបាកចិត្តម្តងហើយម្តងទៀត។ សូមចាំថា ប្រសិនបើអារក្សអាចគ្រប់គ្រងអ្នកគ្រប់កាលៈទេសៈ ម៉្លោះហើយវានឹងធ្វើការសង្កត់អ្នកក្រោមមេដៃវាគ្រប់ពេលវេលា។ អ្នកត្រូវតែដើរក្នុងសិទ្ធិអំណាចរបស់អ្នក ដោយមានសេចក្តីសុខសាន្តជាដរាប ។

# មួយថ្ងៃសំរាប់មួយថ្ងៃ

# ៧

# មួយថ្ងៃសំរាប់មួយថ្ងៃ

មានមធ្យោបាយមួយ ដែលនឹងនាំឱ្យយើងបាត់សេចក្ដីសុខសាន្តគឺការខ្វល់ខ្វាយពីថ្ងៃស្អែក។ ព្រះគម្ពីរម៉ាថាយ៦:៣៤ ថែងថា:

"ដូច្នេះ កុំឱ្យខ្វល់ខ្វាយនឹងថ្ងៃស្អែកឡើយពីព្រោះថ្ងៃស្អែកនឹងខ្វល់ខ្វាយចំពោះការរបស់ថ្ងៃនោះឯងសេចក្ដីលំបាកនៅថ្ងៃណានោះគឺល្មមត្រឹមថ្ងៃនោះបានហើយ"

យើងមួយភាគធំមានរបស់គ្រប់គ្រាន់ល្មមសំរាប់នៅថ្ងៃនេះ ដោយគ្មានការព្រួយបារម្ភសំរាប់ដោះស្រាយពីថ្ងៃស្អែក។ ព្រះជាម្ចាស់នឹងផ្ដល់ព្រះគុណដល់អ្នកសំរាប់ថ្ងៃនេះ។ ព្រះអង្គទ្រង់នឹងផ្ដល់ព្រះគុណដល់អ្នកសំរាប់ថ្ងៃនេះ ប៉ុន្តែព្រះអង្គនឹងមិនផ្ដល់ព្រះគុណឱ្យអ្នកសំរាប់ថ្ងៃស្អែកទេ រហូតដល់ថ្ងៃស្អែកមកដល់សិន។

ជាទូទៅមនុស្សយើងតែងខ្វល់ខ្វាយ ហើយខ្វល់ខ្វាយចំពោះអ្វីមួយដែលមិនទាន់កើតមានឡើងទាល់តែសោះ។ យើងតែងតែសួរថា"ចុះប្រសិនបើវាកើតឡើងមែន?"។ កាលណាអ្នកឮពាក្យ "ចុះប្រសិនបើ..." ចូលមកក្នុងគំនិតរបស់អ្នក ចូរប្រយ័ត្នប្រយែងទៅ។ អ្នកអាចនឹងត្រូវវាទាញឱ្យធ្លាក់ចូលទៅក្នុងការខ្វល់ខ្វាយ។ មនុស្សមួយចំនួនមានការខ្វល់ខ្វាយជាខ្លាំង ដែលការខ្វល់ខ្វាយរបស់ពួកគេក្លាយទៅជាការភ័យខ្លាច ហើយអ្វីៗដែលគេខ្លាចនឹងកើតមានចំពោះជីវិតរបស់ពួកគេ។

យើងអាចទទួលយកពីព្រះជាម្ចាស់តាមរយៈសេចក្តីជំនឿ ។ យើងក៏អាចទទួលយកពីអារក្សផងដែរតាមរយៈការភ័យខ្លាច ។

ចូរកុំបណ្តោយខ្លួនអ្នកឱ្យខ្វល់ខ្វាយពីថ្ងៃស្អែកឡើយ ។ សូមគ្រាន់តែដឹងថាព្រះទ្រង់ស្មោះត្រង់ ។*មិនថាមានអ្វីកើតឡើងនៅថ្ងៃស្អែកទេ ទ្រង់ជ្រាបទាំងអស់*។ព្រះគុណទ្រង់សមល្មមនឹងបំពេញសេចក្តីត្រូវការដែលជួបប្រទះ ។ ចូរកុំឱ្យខ្ជះខ្ជាយព្រះគុណរបស់ទ្រង់នៅថ្ងៃនេះដើម្បីសប្បាយរីករាយថ្ងៃនេះ ដោយការខ្វល់ខ្វាយពីថ្ងៃស្អែកនោះឡើយ ។ វាពិតប្រាកដជាអស្ចារ្យណាស់ដែល យើងសំរេចជោគជ័យក្នុងព្រះគ្រិស្តបាន ប្រសិនបើយើងរស់នៅមួយថ្ងៃសំរាប់មួយថ្ងៃ ។

ខ្ញុំបានរៀនមេរៀននេះ ពេលលខ្ញុំចាប់ផ្តើមបង្រៀន នៅមហាវិទ្យាល័យព្រះគម្ពីរជាលើកដំបូង ។ ខ្ញុំបានបង្រៀនមួយសប្តាហ៍មួយដងនៅក្នុងក្រុមកោសិកាផ្ទះរបស់ខ្ញុំ កន្លែងដែលខ្ញុំធ្វើជាគ្រូគង្វាលជំនួយ ។ ខ្ញុំបានមានកូន៤នាក់ និង មានការងារពេញពេលរួចរាល់ហើយនៅពេលខ្ញុំមានឱកាសបានមកបង្រៀននៅមហាវិទ្យាល័យព្រះគម្ពីរបានពាដងក្នុងមួយសប្តាហ៍នៅឯព្រះវិហារ ។ ខ្ញុំពិតជាបានមានចំណង់បង្រៀនព្រះបន្ទូលថែមទៀត ហើយនេះជាឱកាសរបស់ខ្ញុំមកដល់ដើម្បីបង្រៀនបីដងក្នុងមួយសប្តាហ៍ ។

ប៉ុន្តែ នៅពេលខ្ញុំបង្រៀន ខ្ញុំត្រូវតែរៀនផងដែរ និងរៀបចំមេរៀនទៀត ។ សិស្សជាច្រើនត្រូវរៀនឱ្យស៊ីជំរៅពីព្រះគម្ពីរ ដែលមានន័យថា ខ្ញុំត្រៀមព្រះបន្ទូលឱ្យស៊ីជំរៅដែរ ជាពិសេសសំរាប់មួយឆ្នាំដំបូង ។ ខ្ញុំត្រូវបង្រៀននៅពេលយប់ ពី

ព្រោះខ្ញុំធ្វើការនៅពេលថ្ងៃ។ បើតាមសមត្ថភាព ខ្ញុំមិនអាចធ្វើការអស់ទាំងនេះទេ ប៉ុន្តែខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់ចង់ឱ្យខ្ញុំធ្វើវិញ។

ក្រោយពីបានអធិស្ឋានយ៉ាងច្រើនហើយគិតយ៉ាងយូររួចមក ខ្ញុំចាប់ផ្តើមបោះជំហានក្នុងព្រះជាម្ចាស់ដើម្បីធ្វើកិច្ចការណាដែលយើងគិតថាធ្វើមិនកើតក្នុងទ្រង់។ ការសំខាន់បំផុតនោះគឺថាព្រះអម្ចាស់រំលឹកដាស់តឿនខ្ញុំថា "មួយថ្ងៃម្តង ហើយអ្នកអាចធ្វើវាបាន"។ ប្រសិនបើខ្ញុំចាប់ផ្តើមគិតពីថ្ងៃស្អែក ខ្ញុំងាយនឹងមានបញ្ហាមួយរំពេចពីព្រោះខ្ញុំឃើញថាមិនអាចធ្វើទៅរួច។ អញ្ចឹងចំពោះថ្ងៃនីមួយៗគឺមួយថ្ងៃសំរាប់មួយថ្ងៃ, នេះជាអ្វីដែលយើងត្រូវធ្វើ។ ព្រះជាម្ចាស់បានផ្តល់ព្រះគុណដល់ខ្ញុំ ប៉ុន្តែរហូតដល់ថ្ងៃដែលខ្ញុំត្រូវការប៉ុណ្ណោះ។ នៅឆ្នាំទី២ ខ្ញុំស្រួលជាងឆ្នាំទី១ ព្រោះខ្ញុំមានមេរៀនទាំងអស់។ ដូច្នេះ ខ្ញុំមិនចាំបាច់រៀនច្រើនដូចឆ្នាំទី១ទេ។

មានមូលហេតុសំខាន់ពីរយ៉ាងដែលព្រះអម្ចាស់ដោះស្រាយភារៈកិច្ចនេះ ក្រៅពីការបង្រៀនព្រះបន្ទូលដល់កូនសិស្ស។ ទីមួយគឺឱ្យខ្ញុំទទួលបទពិសោធន៍ជាមុនថាតើត្រូវសំរេចជោគជ័យបានប៉ុណ្ណាតាមរយៈព្រះគុណនៃព្រះជាម្ចាស់ ប្រសិនបើរស់នៅមួយថ្ងៃសំរាប់មួយថ្ងៃនោះ។ ទីពីរ ឱ្យខ្ញុំទទួលបទពិសោធន៍អំពីការបង្រៀន។ ឥឡូវខ្ញុំបង្រៀនជាញឹកញាប់ ដូចដេវប្តីខ្ញុំនិងខ្ញុំធ្វើដំណើរទៅបង្រៀនបន្ថែមធ្វើឱ្យជីវិត "រស់នៅក្នុងព្រះបន្ទូល" ទ្រង់ស្មោះត្រង់ហើយផ្លូវទ្រង់គ្រប់លក្ខណ៍។

ផ្នែកដទៃទៀត ស្ថិតនៅតាមខ្សែបន្ទាត់នេះ ដែលធ្វើឱ្យមនុស្សមានបញ្ហាគឺវិប្បដិសារី រស់នៅក្នុងវិប្បដិសារីពីអតីតកាល។ គ្មាននរណាម្នាក់មិនដែលធ្វើខុសទេ។ ខ្ញុំនិយាយថា "ចាំ យើងតែងតែធ្វើខុស"។ ទោះបីជាមនុស្សដែលអ្នក

គិតថាខ្លួនមិនដែលធ្វើខុសក៏ធ្វើខុសដែរ ។ ព្រះគម្ពីរចែងថា ត្បិតគ្រប់គ្នាត្រូវទទួលបន្ទុកជារបស់ផងខ្លួន( កាឡាទី៦:៥) ។ យើងទាំងអស់គ្នាបាននិយាយនិង ប្រព្រឹត្តនូវអ្វីដែលយើងមិនបានប្រាថ្នាចង់ធ្វើ ។ម្តងអ្វីមួយត្រូវបានធ្វើគឺវាធ្វើរួចទៅហើយ ។

ខ្ញុំបានរៀនថា ជាការប្រសើរជាងការបាត់បង់សេចក្តីសុខសាន្តពីលើអ្វីមួយដែលខ្ញុំបានធ្វើ ប៉ុន្តែមិនអាចធ្វើអ្វីទាំងអស់ពេលនេះ, ខ្ញុំគួរតែទុកចិត្តព្រះជាម្ចាស់ក្នុងការធ្វើអ្វីមួយឱ្យត្រឹមត្រូវ ។ តើអ្នកដឹងទេថា ទ្រង់មានលទ្ធភាពអាចធ្វើបានគ្រប់ទាំងអស់ ។ ទ្រង់អាចលុបចោលកំហុសឆ្គងយើងទាំងអស់បាន ។

ជួនកាលខ្ញុំនិយាយអ្វីដែលខ្ញុំគិតថាមិនគួរនិយាយទាល់តែសោះ ។ ជំនួសការខ្វល់ខ្វាយថា តើខ្ញុំគួរការពារ ឬធ្វើឱ្យអ្នកណាម្នាក់ខឹងនឹងខ្ញុំ តែខ្ញុំទូលសូមដល់ព្រះអម្ចាស់ឱ្យគេយល់ចិត្ត ទោះបីខ្ញុំធ្វើឱ្យគេអាម៉ាស់មុខក៏ដោយ ។ ខ្ញុំទុកចិត្តដល់ទ្រង់ថានឹងធ្វើការក្នុងចិត្តគេ ហើយក៏ធ្វើឱ្យខ្ញុំស្ងប់ចិត្តផងដែរ ។ បើដូច្នោះខ្ញុំមិនចាំបាច់ចំណាយពេលខ្វល់ខ្វាយច្រើនថ្ងៃ ហើយដើរគេចមុខកាលណាដើរជួបគេម្តងៗនោះទេ ។

យើងបានធ្លាក់ក្នុងអន្ទាក់នៃ ការសោកស្តាយដោយសាររឿងជាច្រើន ។ ខ្ញុំនិងប្តីខ្ញុំញ៉ាំអាហារនៅខាងក្រៅជាញឹកញាប់ពីព្រោះមមារញឹកនឹងការងារខ្លាំងពេក ។ ថៃដន្យពេលខ្លះ យើងបានញ៉ាំនៅហាងមិនឆ្ងាញ់ ឬ សេវាកម្មខ្សោយ មិនល្អ ។ ពេលយើងចេញមកវិញ យើងសោកស្តាយដោយសារទៅញ៉ាំនៅទីនោះ ។ ព្រះអម្ចាស់បានបង្ហាញឱ្យយើងដឹងថា ទោះបីជាយើងសោកស្តាយដោយរើសភោជនីយដ្ឋានខុសក៏ដោយ ក៏វានឹងលួចសេចក្តីសុខសាន្តរបស់យើងបាត់ដែរ ។

# មួយថ្ងៃសំរាប់មួយថ្ងៃ

ចូរចាំថា ដើម្បីអរសប្បាយសេចក្ដីសុខសាន្ត ត្រូវឈប់ព្យាយាមធ្វើអ្វីមួយ ដែលអ្នកមិនអាចធ្វើទៅបាន។ កាលណាអ្នកជួយឧបត្ថម្ភមុខជំនួញណាមួយ ហើយ អ្នកបានបង់លុយរួចហើយ នោះការសោកស្ដាយក៏មិនកែប្រែអ្វី ដែលបានកើត ឡើងរួចមកហើយដែរ។

ឥឡូវនេះ យើងក្រឡេកមើលសណ្ឋានភាពជុំវិញយើង ហើយឱ្យការងារប្រ ព្រឹត្តទៅជាប្រក្រតីចុះ។ ឥឡូវនេះ យើងនិយាយថា "ចូរគិតដល់មនុស្សទាំងអស់ ដែលទៅភោជនីយដ្ឋាននោះថាតើពួកគេខកចិត្តប៉ុណ្ណា។ តើយើងមិនបានពរទេឬ អី? យើងបានដឹងរួចមកហើយថានោះមិនមែនជាកន្លែងដែល យើងគួរទៅទេ។ យើងនឹងមិនខ្ជះខ្ជាយពេលវេលា និង ប្រាក់កាសនៅទីនោះម្ដងទៀតឡើយ"។

ខ្ញុំបិទក្រដាសមួយផ្ទាំងលើជញ្ជាំងរបស់ខ្ញុំដោយសរសេរថា: "បើសិនអ្នកព្យា យាមរស់នៅក្នុងអតីតកាល នោះជីវិតអ្នកនឹងយ៉ាប់យ៉ឺន ។ ព្រះយេស៊ូមិនបានមាន បន្ទូលថា ទ្រង់បានអស្ចារ្យ "កាលពីមុន" ទេ។ ប្រសិនបើខ្ញុំព្យាយាមរស់នៅក្នុង អនាគតកាល នោះជីវិតនឹងមានការ លំបាកដូចគ្នាដែរ។ ព្រះយេស៊ូក៏មិនបានមាន បន្ទូលថា ទ្រង់នឹងអស្ចារ្យ "នៅអនាគត"ដែរ។ បើអ្នករស់នៅថ្ងៃនីមួយៗសំរាប់ មួយថ្ងៃ នោះជីវិតអ្នកនឹងប្រព្រឹត្តទៅជាប្រក្រតី។ ព្រះយេស៊ូមានបន្ទូលថា "គឺខ្ញុំ" (យ៉ូហាន៨:៥៨) ទ្រង់តែងតែគង់ នៅជាមួយអ្នកគ្រប់ស្ថានការណ៍ដែលកើតមាន ឡើង។ សូមឱ្យគ្រាន់តែចាំថា ទុកចិត្តលើព្រះគុណទ្រង់ល្មមចំពោះអ្នកសំរាប់នៅ ថ្ងៃនេះ។

# ការអធិស្ឋាននាំមកនូវ
# សន្តិភាព

# ៨

# ការអធិស្ឋាននាំមកនូវសន្តិភាព

ព្រះគម្ពីរភីលីព៤:៦-៧ ចែងថា:

"កុំឱ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះឱ្យជ្រាបពីសេចក្ដីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ដោយសេចក្ដីអធិស្ឋាន និងពាក្យទូលអង្វរទាំងពោលពាក្យអរព្រះគុណផង"។

"យ៉ាងនោះសេចក្ដីសុខសាន្តរបស់ព្រះដែលហួសលើសពីអស់ទាំងគំនិត នឹងជួយការពារចិត្ត ហើយនឹងគំនិតរបស់អ្នករាល់គ្នាក្នុងព្រះគ្រិស្តយេស៊ូ"។

សេចក្ដីសុខសាន្តដែលហួសលើសអស់ទាំងគំនិត ដែលយល់ដឹងគឺជារឿងដ៏អស្ចារ្យដើម្បីទទួលបានបទពិសោធន៍។ នៅពេលយោងទៅតាមគ្រប់កាលៈទេសៈទាំងអស់ អ្នកអាចនឹងទទួលការបាក់ទឹកចិត្ត នៅក្នុងភាពចលាចល ភាពភ័យតក់ស្លុត ហើយនឹងខ្វល់ខ្វាយ ប៉ុន្តែអ្នកបែរជាមានសេចក្ដីសុខសាន្តដែលមិនអាចពិពណ៌នាបានទៅវិញ នោះបង្ហាញថាអ្នកបានឆ្លងកាត់បទពិសោធន៍ដ៏អស្ចារ្យមួយ។ លោកិយប្រាថ្នាចង់បានសេចក្ដីសុខសាន្តបែបនេះ។ អ្នកមិនអាចទិញវាបានទេ ហើយ វាក៏មិនមែនសំរាប់ដាក់លក់ដែរ។ សេចក្ដីសុខសាន្តនេះជារបស់ផងអ្នកនៅពេលដែលអ្នកទទួលព្រះយេស៊ូទុកដូចជាព្រះជាម្ចាស់ និង ជាព្រះសង្គ្រោះរបស់

អ្នកផ្ទាល់ ព្រមទាំងរៀនដើរតាមគោលការណ៍គ្រឹះរបស់ទ្រង់។

ការប្តូរផ្តាច់ក្នុងសេចក្តីអធិស្ឋាន គឺជាការអធិស្ឋានពេញដោយអំណាចចេស្តា ដែលរើអស់ទាំងបន្ទុករបស់អ្នកទៅលើព្រះយេស៊ូ។ ១.ពេត្រុស៥:៧ ចែងថា "ចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ត្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា"។

តើអ្វីទៅជា*អភ័យឯកសិទ្ធិ!* មានគ្រិស្តបរិស័ទជាច្រើន មិនដែលទាញយកផលប្រយោជន៍ពីអភ័យឯកសិទ្ធិនេះទេទោះបីជាវាជារបស់ពួកគេក៏ដោយ។

តើអ្នកអរសប្បាយនឹងសេចក្តីសុខសាន្ត ដែលបានទទួលក្រោយពីផ្ទេរអស់ទាំងបន្ទុករបស់អ្នករាល់គ្នាទៅលើទ្រង់ដែរឬទេ? ពាក្យផ្ទេរមានន័យថា ដក ឬចោលឱ្យអស់ដោយឥតសំចៃទុកអ្វីសោះ។កាលណាអ្នកផ្ទេរកាន់តែឆាប់ នោះកាន់តែល្អ។ អ្នកអាចផ្ទេរការនេះបានតាមរយៈការអធិស្ឋាន។ ចូរថ្វាយបញ្ហារបស់អ្នកទៅដល់ទ្រង់ដែលពោរពេញទៅដោយព្រះទ័យស្រឡាញ់យកចិត្តទុកដាក់។ចូរធ្វើភ្លាម កាលណាព្រះវិញ្ញាណបរិសុទ្ធដាស់តឿនឱ្យដឹងថា អ្នកកំពុងតែខ្វល់ខ្វាយ ឬក៏អ្នកបាត់បង់សេចក្តីសុខសាន្តហើយ។

អារក្សចង់ឱ្យអ្នកខ្វល់ខ្វាយ។ ព្រះគម្ពីរ១.ពេត្រុស៥:៩ ចែងថា "ចូរតស៊ូនឹងវា ដោយមានចិត្តជឿមាំមួន ទាំងដឹងថា ពួកបងប្អូនរបស់អ្នករាល់គ្នាដែលនៅក្នុងលោកិយនេះគេកំពុងតែរងទុក្ខលំបាកដូចគ្នាដែរ"។កុំឱ្យរងចាំរហូតដល់ខ្មាំង សត្រូវមានឱកាសធ្វើការច្រើនថ្ងៃមុនអ្នកឱ្យសោះ។កាលណាអ្នករងចាំកាន់តែយូរអារក្សកាន់តែខ្លាំងមាំមួនដែលធ្វើឱ្យអ្នកពិបាកតតាំងយកឈ្នះ។ បន្ទាប់មកអ្នកនឹងពិបាក

កំចាត់វាណាស់។ ដរាបណាអ្នកដឹងថាអ្នកកំពុងតែខ្វល់ខ្វាយ ចូរបដិសេធនឹការខ្វល់ខ្វាយចេញទៅ។ ចូរផ្ទេរការខ្វល់ខ្វាយគ្រប់ស្ថានការណ៍របស់អ្នកដល់ព្រះជាម្ចាស់។ ចូរបំផ្លាស់បំប្រែផ្នត់គំនិតនៃការគិតរបស់អ្នកចេញ។

នៅពេលខ្ញុំបានរៀនដំបូងអំពីគោលការណ៍នៃ "ការផ្ទេរសេចក្តីទុក្ខព្រួយរបស់ខ្ញុំ" ហើយ "ការមិនខ្វល់ខ្វាយ" ខ្ញុំបានដឹងថា គំនិតរបស់ខ្ញុំគិតខុស។ ខ្ញុំបានចំណាយពេលពេញមួយថ្ងៃ ផ្ទេរការស្រមើស្រមៃទាំងនោះចេញ តែវាចេះតែវិលត្រឡប់មកវិញមួយរំពេច។ ខ្ញុំបានចាំថា ខ្ញុំធុញទ្រាន់គ្រប់រឿងរ៉ាវតែម្តង។ ខ្ញុំបានទូលទៅព្រះអម្ចាស់ថា "តើធ្វើដូចម្តេចមិនឱ្យមនុស្ស មិនគិតពីអ្វីសោះនោះបាន?" អ្នកឃើញទេថា ដើម្បីកុំឱ្យខ្វល់ខ្វាយ អ្នកត្រូវតែមិនគិតពីបញ្ហាអ្វីទាំងអស់។ កាលណាអ្នកត្រូវការគិតដើម្បីធ្វើសេចក្តីសំរេចចិត្ត អ្នកនឹងគិតពីវិជ្ជមាន មិនមែនអវិជ្ជមានទេ។ អ្នកអាចនិយាយពីការពិតពីបញ្ហារបស់អ្នក តែមិនមែនអវិជ្ជមានទេ។

ខ្ញុំនៅតែចងចាំជាប់ជានិច្ច នូវអ្វីដែលព្រះយេស៊ូមានបន្ទូលមកកាន់ខ្ញុំនៅពេលខ្ញុំទូលទៅទ្រង់ថា "តើមិនឱ្យខ្ញុំមិនគិតពីបញ្ហាដូចម្តេចបាន? ព្រះទ្រង់បានមានបន្ទូលឆ្លើយថា "ចយស៍, វាជារឿងសាមញ្ញទេ! គឺឯងគ្រាន់តែគិតពីរឿងផ្សេងទៅវាបានហើយ។ អ្នកឃើញទេអ្នកមិនអាចគិតពីបញ្ហាបានទេ បើសិនជាអ្នកគិតពីរឿងអ្វីមួយផ្សេងទៀតដែលមិនមែនជាបញ្ហា។

គម្ពីរភីលីព៤:៦ ចែងថា "សូមកុំខ្វល់ខ្វាយនឹងអ្វីឡើយ ផ្ទុយទៅវិញ ក្នុងគ្រប់កាលៈទេសៈទាំងអស់ ត្រូវទូលព្រះជាម្ចាស់ឱ្យជ្រាបពីសំណូមពររបស់បងប្អូន ដោយអធិស្ឋាន និង ទូលអង្វរ ទាំងអរព្រះគុណព្រះអង្គផង។ ក្នុងខ៧មានសេចក្តី

សន្យាថា បើសិនបើអ្នកធ្វើតាមខ៦ នោះអ្នកនឹងបានសេចក្ដីសុខសាន្ដដែលហួសពីការគិតរបស់អ្នក។ ក្នុងខ៨ចែងថាៈ

"មួយទៀតបងប្អូនអើយ ឯសេចក្ដីណាដែល ពិត សេចក្ដីណាដែលគួររាប់អាន សេចក្ដីណាដែលសុចរិត សេចក្ដីណាដែលបរិសុទ្ធ សេចក្ដីណាដែលគួរស្រឡាញ់ សេចក្ដីណាដែលមានឈ្មោះល្អ បើមានសគុណណា ឬជាសេចក្ដីសរសើរណា នោះចូរពិចារណាពីសេចក្ដីទាំងនោះចុះ"។

ឥឡូវនេះខ្ញុំអធិស្ឋានថា សូមព្រះជាម្ចាស់ ប្រទានព្រះគុណដល់អ្នករាល់គ្នាដែលជាអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ក្នុងការដាក់គោលការណ៍ទាំងនេះ ទៅជាការអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ហេតុដូចនេះ អ្នករាល់គ្នាមានអំណរនឹងព្រះពរក្នុងជីវិត ដែលពោរពេញដោយសេចក្ដីសុខសាន្ដ។ ខ្ញុំក៏អធិស្ឋានផងដែរថា សូមឱ្យព្រះបិតាប្រើប្រាស់អ្នកដើម្បីថ្វាយសេរីរុងរឿង និងព្រះកិត្តិនាមដល់ទ្រង់វិញ។

# បទពិសោធន៍ក្នុងជីវិតថ្មី

ប្រសិនបើអ្នកមិនទាន់បានយាងព្រះយេស៊ូធ្វើជាព្រះអម្ចាស់ ហើយជាព្រះអង្គសង្គ្រោះរបស់អ្នកនៅឡើយ ខ្ញុំសូមឱ្យអ្នកយាងទ្រង់ចូលមកគង់ក្នុងជីវិតរបស់អ្នកឥឡូវនេះចុះ។ អ្នកអាចអធិស្ឋានតាមលំនាំបែបនេះ ហើយបើអ្នកមានភាពស្មោះត្រង់ចំពោះសេចក្តីទាំងអម្បាលម៉ានដែលអ្នកបានអធិស្ឋាន នោះអ្នកពិតជាទទួលនូវបទពិសោធន៍ថ្មី សំរាប់ជីវិតរបស់អ្នកក្នុងព្រះគ្រិស្ត។

លំនាំនៃសេចក្តីអធិស្ឋានៈ *"ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌អើយ ទូលបង្គំជឿថា ព្រះយេស៊ូជាព្រះរាជបុត្រានៃព្រះ ហើយជាព្រះអង្គសង្គ្រោះនៃមនុស្សលោក។ ទូលបង្គំជឿថា ទ្រង់បានសុគតនៅលើឈើឆ្កាងដើម្បីលោះបាបទាំងអស់របស់ទូលបង្គំ។ ទ្រង់សងថ្លៃលោះបាបទូលបង្គំ ព្រមទាំងទទួលរងទារុណកម្មដែលទូលបង្គំត្រូវទទួលនោះ។ ទូលបង្គំជឿថា ព្រះយេស៊ូមានព្រះជន្មរស់ពីសុគតឡើងវិញ ហើយឥឡូវនេះ ទ្រង់គង់នៅខាងស្តាំដៃនៃព្រះវរបិតា។ ទូលបង្គំត្រូវការទ្រង់ព្រះយេស៊ូអើយ សូមអត់ទោសបាបទូលបង្គំផង។ សូមជួយសង្គ្រោះទូលបង្គំ សូមយាងមកគង់នៅក្នុងជីវិតទូលបង្គំ ទូលបង្គំចង់កើតជាថ្មី"* ។

ឥឡូវនេះសូមជឿថាព្រះយេស៊ូកំពុងតែគង់នៅក្នុងចិត្តអ្នក។ អ្នកបានទទួលការអត់ទោសពីព្រះជាម្ចាស់ហើយ និងត្រឡប់ជាមនុស្សសុចរិតនៅចំពោះព្រះជាម្ចាស់។ ម្យ៉ាងទៀតនៅពេលព្រះយេស៊ូយាងមកវិញ អ្នកនឹងបានចូលទៅក្នុងនគរស្ថានសួគ៌ ។

ចូរស្វែងរកព្រះវិហារណាមួយដែលបង្រៀនព្រះបន្ទូលបានល្អត្រឹមត្រូវ ដើម្បីឱ្យអ្នកបានចូលរៀនព្រះបន្ទូល ហើយចាប់ផ្តើមរីកចំរើនក្នុងព្រះគ្រិស្ត ។ គ្មានអ្វីមួយដែលអាចជួយបំផ្លាស់បំប្រែជីវិតរបស់អ្នកបាន ក្រៅតែពីការស្គាល់នូវព្រះបន្ទូលទ្រង់ឡើយ ។ ក្នុងព្រះគម្ពីរយ៉ូហាន៨:៣១-៣២ បានចែងថា "នោះព្រះយេស៊ូមានបន្ទូលទៅពួកសាសន៍យូដា ដែលជឿដល់ទ្រង់ថា បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសអ្នកឱ្យរួច" ។

បងប្អូនបុគ្គលិកនៅ "ជីវិតក្នុងព្រះបន្ទូល" ទាំងអស់ស្រឡាញ់បងប្អូនណាស់ ។ យើងសូមអធិស្ឋានឱ្យបងប្អូន បានទទួលព្រះពរតាមរយៈសៀវភៅនេះពោរពេញទៅដោយសេចក្តីសុខសាន្ត ។

# ជូនចំពោះបងប្អូនជាទីស្រឡាញ់

ព្រះគម្ពីរយ៉ូហាន៨:៣១-៣២ បានចែងថា "នោះព្រះយេស៊ូមានបន្ទូលទៅពួកសាសន៍យូដាដែលជឿដល់ទ្រង់ថា បើអ្នករាល់គ្នានៅជាប់ក្នុងពាក្យខ្ញុំ នោះអ្នករាល់គ្នាជាសិស្សខ្ញុំមែន អ្នករាល់គ្នានឹងស្គាល់សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសអ្នកឱ្យរួច"។

ខ្ញុំទូន្មានឱ្យបងប្អូនកាន់ខ្ជាប់តាមព្រះបន្ទូលព្រះជាម្ចាស់ ហើយដាំឱ្យជ្រៅក្នុងដួងចិត្តអ្នករាល់គ្នា។ យោងតាមព្រះគម្ពីរ ២.កូរិនថូស៣:១៨ ចែងថា " ហើយយើងរាល់គ្នាទាំងអស់ដែលកំពុងតែរំពឹងមើលសិរីល្អព្រះអម្ចាស់ទាំងមុខទទេ ដូចជាឆ្លុះមើលទ្រង់ក្នុងកញ្ចក់ យើងកំពុងតែផ្លាស់ប្រែទៅឱ្យដូចជារូបឆ្លុះនោះឯង ពីសិរីល្អទៅដល់សិរីល្អ គឺដោយសារព្រះអម្ចាស់ដ៏ជាព្រះវិញ្ញាណ"។ នៅពេលដែលពិភពលោកនេះមើលមកអ្នក អ្នកត្រូវបានបំផ្លាស់បំប្រែឱ្យទៅជារូបភាពដូចព្រះគ្រិស្ត។

ដោយសេចក្តីស្រឡាញ់

ចយស៊ី

# អំពីអ្នកនិពន្ធ

អ្នកស្រី ចយស៍ ម៉ៃយ័រ **Joyce Meyer** បាននឹងកំពុងតែ បង្រៀនព្រះបន្ទូលចាប់តាំងពីឆ្នាំ១៩៧៦ ហើយ ចូលបំរើពេញពេលក្នុងព័ន្ធកិច្ចចាប់តាំងពីឆ្នាំ១៩៨០។ អ្នកស្រី គឺជាអ្នកនិពន្ធលក់សៀវភៅដាច់បំផុតដែលមាន៥៤សៀវភៅខុសៗគ្នា រួមទាំងសៀវភៅ អាថ៌កំបាំងនៃជីវិតរស់នៅ, អំណរនៃសេចក្តីជំនឿអធិស្ឋាន និង សៀវភៅសមរភូមិនៃគំនិត ព្រមទាំងមានឃុតមេរៀនជាកាសែតស្តាប់សម្លេងជាង២២០ឃុត ហើយជាង ៩០ឃុតកាសែតវិដេអូ។ កម្មវិធីវិទ្យុនិងទូរទស្សន៍"ជីវិតរីករាយ"ត្រូវបានចាក់ផ្សព្វផ្សាយពាសពេញពិភពលោក ហើយអ្នកស្រី ធ្វើដំណើរយ៉ាងមមាញឹកដើម្បី ចែកចាយព្រះបន្ទូលនៅក្នុងសន្និបាតនានាជុំវិញពិភពលោក "ជីវិតក្នុងព្រះបន្ទូល"។ អ្នកស្រី ចយស៍ និង ប្តីរបស់អ្នកស្រី គឺជាឪពុកម្តាយដែលមានកូនបួននាក់ និងមានទីលំនៅ ក្នុងទីក្រុង **St.Louis** រដ្ឋ **Missouri** សហរដ្ឋអាមេរិក។

# ការអធិស្ឋានដើម្បីបានសង្គ្រោះ

"ព្រះអម្ចាស់ស្រឡាញ់អ្នក ហើយចង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នក។ បើសិនជា អ្នកមិនទាន់ទទួលព្រះយេស៊ូគ្រិស្តជាព្រះអង្គសង្គ្រោះរបស់អ្នកនៅឡើយ នោះអ្នកអាចទទួលឥឡូវនេះបាន។ សូមបើកចំហដួងចិត្តរបស់អ្នកចំពោះព្រះអង្គ និង អធិស្ឋានដូចខាងក្រោម:

"ឱព្រះវរបិតាអើយទូលបង្គំដឹងថាទូលបង្គំមានបាបទាស់នឹងព្រះអង្គ។ សូម អត់ទោសបាបដល់ទូលបង្គំ សូមលាងសំអាតទូលបង្គំ។ ទូលបង្គំសន្យាថា ទុកចិត្តព្រះយេស៊ូជាព្រះរាជបុត្រារបស់ព្រះអង្គ។ ទូលបង្គំជឿថាព្រះយេស៊ូ សុគតដោយព្រោះទូលបង្គំ ព្រះអង្គទ្រង់បានយកបាបរបស់ទូលបង្គំដាក់ លើអង្គទ្រង់នៅពេលទ្រង់សុគតនៅលើឈើឆ្កាង។ ទូលបង្គំជឿថាព្រះអង្គ បានមានព្រះជន្មរស់ពីសុគតឡើងវិញ។ ទូលបង្គំសូមថ្វាយជីវិតដាច់ដល់ ព្រះអង្គឥឡូវនេះ។ ទូលបង្គំ សូមអរព្រះគុណដល់ព្រះវរបិតាដែលបានប្រ ទានការអត់ទោសនិងជីវិតអស់កល្ប។សូមព្រះអង្គជួយដល់ទូលបង្គំដើម្បីរស់នៅសំរាប់ព្រះអង្គ។ ទូលបង្គំអធិស្ឋាន ក្នុងព្រះនាមព្រះយេស៊ូគ្រិស្ត! អាម៉ែន។"

នៅពេលអ្នកអធិស្ឋានចេញពីដួងចិត្តរបស់អ្នក ព្រះជាម្ចាស់បានទទួលយកអ្នក សំអាតអ្នក និងរំដោះអ្នកឲ្យមានសេរីភាពពីចំណងនៃសេចក្តីស្លាប់ខាងវិញ្ញាណ។ សូមចំណាយពេលអាននិងសិក្សាព្រះបន្ទូលទាំងនេះ ហើយទូលសូមព្រះជាម្ចាស់ដើម្បីនិយាយទៅកាន់អ្នក ដូចជាអ្នកដើរជាមួយទ្រង់តាមរយៈដំណើរនេះនៅក្នុងជីវិតថ្មីរ។

| | |
|---|---|
| យ៉ូហាន ៣:១៦ | ១កូរិនថូស ១៥:៣-៤ |
| ១ យ៉ូហាន ១:៩ | ១ យ៉ូហាន ៤:១៤-១៥ |
| អេភេសូរ ១:៤ | អេភេសូរ ២:៨-៩ |
| ១ យ៉ូហាន ៥:១ | ១ យ៉ូហាន ៥:១២-១៣ |

សូមអធិស្ឋាននិងទូលសុំព្រះឲ្យជួយអ្នករកបានព្រះវិហារ ដែលមានជំនឿតាមព្រះគម្ពីរ ដែលអាចជួយអ្នកឲ្យរីកចំរើននៅក្នុងទំនាក់ទំនងរបស់អ្នកជាមួយព្រះគ្រិស្ត។ ព្រះជាម្ចាស់គង់ជាមួយអ្នកជានិច្ច។ ព្រះទ្រង់នឹងដឹកនាំអ្នកពីមួយថ្ងៃទៅមួយថ្ងៃ ហើយនឹងបង្ហាញអ្នកពីរបៀបរស់នៅជីវិតពេញបរិបូរដែលព្រះអង្គមានសំរាប់អ្នក!